សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de Droit et des Sciences Economiques

Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# មូលហេតុដែលរួចផុតពីការ ទទួលខុសត្រូវព្រហ្មទណ្ឌ

ស្រាវជ្រាវពីថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៦ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៦


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **សុធា រស្មី**

សាស្ត្រាចារ្យណែនាំ

លោក **ជួន ម៉ុនធី**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ១៦

ឆ្នាំចូលសិក្សា ២០១២

ឆ្នាំសរសេរសារណា ២០១៦

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទឈ្មោះ **សុធា រស្មី** និង មិត្តរួមក្រុមឈ្មោះ **អៀង វណ្ណៈ** ជានិស្សិតថ្នាក់បរិញ្ញាបត្រឆ្នាំទី ០៤ ផ្នែកនីតិសាស្ត្រ ជំនាន់ទី១៦ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ក្នុងឆ្នាំសិក្សា ២០១២-២០១៦

**យើងខ្ញុំទាំងពីរសូមលំអោនកាយ វាចា ចិត្ត គោរព និង សំដែងនូវមហាកតញ្ញូតាធម៌ដឹងគុណយ៉ាងធំធេងបំផុតជូនចំពោះអ្នកមានគុណរួមមាន:**

**លោកឪពុក អ៊ុច សុធា** **អ្នកម្តាយ យុន គន្ធា**

**លោកឪពុក អៀង ស្រ៊ី** **អ្នកម្តាយ ស៊ែម យុន**

ដែលលោកបានផ្តល់កំណើត ព្រមទាំងចិញ្ចឹមបីបាច់ថែរក្សា រូបកូនតាំងពីតូចមានវ័យកុមារ រហូតដល់កូនចំរើនវ័យមកដល់ថ្ងៃនេះ ។ មិនតែប៉ុណ្ណោះលោកទាំងពីរបានបង្រៀន ប្រៀនប្រដៅកូនជាមួយនឹងដំបូន្មានល្អៗក្នុងជីវិតនឹងរហូតដល់កូនទទួលបានជោគជ័យ ជាមួយនឹងលទ្ធផលជាទីគាប់ប្រសើរនាថ្នាក់ឧត្តមសិក្សានេះ ។ សូមលោកទាំងពីរ មេត្តាទទួលនូវការគោរព និង ការដឹងគុណពីកូនប្រុសរបស់លោកទាំងពីរ។

**ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង លោក លោកស្រីដែលជាព្រឹទ្ធបុរស លោកគ្រូ អ្នកគ្រូដែលជាសាស្ត្រាចារ្យទាំងអស់** នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលលោកមានសមត្ថភាព និងចំណេះដឹងខ្ពង់ខ្ពស់ក្នុងការជួយតម្រង់ទិសដៅដល់រូបខ្ញុំបាទទាំងពីរ តាំងពីការសិក្សាថ្នាក់មូលដ្ឋានរហូតដល់ថ្នាក់បញ្ចប់បរិញ្ញាបត្រនេះ ប្រកបដោយក្រមសីលធម៌ វិជ្ជាជីវៈ ។

ជាពិសេសជូនចំពោះលោកសាស្ត្រាចារ្យ **ខួន ម៉ុនធី** ដែលលោកគ្រូបានបង្ហាត់បង្ហាញនូវគំនិតក៏ដូចជាវិធីសាស្ត្រជាច្រើននៅក្នុងការស្រាវជ្រាវនូវប្រធាបទមួយនេះ ដោយលោកគ្រូបានខិតខំចំណាយពេលវេលាដ៏មានតម្លៃរបស់លោកគ្រូ ក្នុងការជួយជ្រោមជ្រែងការស្រាវជ្រាវមួយនេះ តាំងពីដើមរហូតដល់ទីបញ្ចប់។ សារណាមួយនេះចេញជារូបរាងទៅបាន ក៏អាស្រ័យដោយមានលោកសាស្ត្រាចារ្យជាអ្នកណែនាំ។

លោក លោកស្រីដែលជាបណ្ណារក្ស និស្សិតរៀមច្បង និងមិត្តនិស្សិតទាំងអស់ដែលបានគាំទ្រជាសម្ភារៈ ក៏ដូចជាកម្លាំងចិត្ត ព្រមទាំងផ្តល់ជាគំនិតយោបល់ល្អៗ ជំរុញឲ្យការស្រាវជ្រាវមានលក្ខណៈកាន់តែល្អប្រសើរឡើង ដើម្បីទុកជាឯកសារក្នុងការស្រាវជ្រាវ ព្រមជាមួយនឹងការស្វែងយល់ ជាមួយមឹងចំនេះដឹងបន្ថែមដល់មិត្តនិស្សិតជំនាន់ក្រោយទៀត ។

ជាចុងក្រោយខ្ញុំបាទ សូមគោរព ជូនពរ ចំពោះលោកអ្នកមានគុណដូចដែលបានរៀបរាប់ខាងលើឲ្យជួបប្រទះនូវពុទ្ធពរ ទាំងបួនប្រការគឺ **អាយុ វណ្ណៈ សុខៈ ពលៈ** និងសេចក្តីសុខចម្រើន ចូលកើតមានដល់លោកអ្នកដ៏មានគុណទាំងអស់កុំបីឃ្លាងឃ្លាតឡើយ។

# អារម្ភកថា

ក្នុងនាមខ្ញុំបាទ ជានិស្សិតថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រ ជំនាន់ទី ១៦ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចក្នុងឆ្នាំសិក្សា២០១២-២០១៦ ។ ក្នុងឱកាសដ៏វិសេសវិសាលដែលសាកលវិទ្យាល័យផ្តល់ឲ្យបែបនេះ ខ្ញុំបាទ និងមិត្តរួមក្រុមបានសម្រេចជ្រើសរើស និងរៀបចំស្រាវជ្រាវតាក់តែងនូវសារណាមួយក្រោមប្រធានបទ **មូលហេតុដែលរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌ** ដែលវាចេញពីការខិតខំប្រឹងប្រែងសិក្សា និងចំណេះដឹងនាពេលកន្លងមក ។

ការស្រាវជ្រាវនូវប្រធានបទមួយនេះ ទៅលើមូលហេតុដែលជាលក្ខខណ្ឌ និងមូលហេតុផ្សេងទៀតដែលនាំឲ្យរលត់បណ្តឹងអាជ្ញា នៅពេលដែលរូបវន្តបុគ្គល ឬ នីតិបុគ្គលបានប្រព្រឹត្តនូវអំពើរំលោភបំពានណាមួយដែលច្បាប់ចាត់ទុកថាជាអំពើដែលបង្កគ្រោះថ្នាក់ដល់សង្គម អសន្តិសុខ និងអន្តរាយដល់ទំនាក់ទំនងក្នុងសង្គម ដែលកំពុងកើតឡើងស្របជាមួយមូលហេតុនៃការរលត់បណ្តឹងអាជ្ញាដែលច្បាប់បានកំណត់ ។ គោលបំណងមួយទៀត គឺដើម្បីឆ្លើយតបទៅនឹងទំហំទឹកចិត្តដ៏ធំធេងពីសំណាក់លោកគ្រូសាស្ត្រាចារ្យ **ជួន ម៉ុនធី** ក្នុងនាមដែលលោកបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការណែនាំ ចង្អុលបង្ហាញ និងចែករំលែកនូវចំណេះដឹងព្រមទាំងបទពិសោធន៍សំរាប់ជាស្ពានក្នុងការស្រាវជ្រាវនូវប្រធានបទមួយនេះ ។ រួមនឹងការយកចិត្តទុកដាក់ពីសំណាក់គ្រូសាស្ត្រាចារ្យ ក្នុងការបណ្តុះបណ្តាល និងសម្របសម្រួលដល់ពួកយើង រួមនឹងការខិតខំប្រឹងប្រែងសិក្សា និងការស្រាវជ្រាវដោយខ្លួនឯងផ្ទាល់បន្ថែមទៀតទើបធ្វើឲ្យសារណាមួយនេះលេចជារូបរាងឡើង ។

ទន្ទឹងនឹងនេះប្រធានបទខាងលើនេះ មានលក្ខណៈសមស្របទៅនឹងកំណែទម្រង់ប្រព័ន្ធច្បាប់នៃព្រះរាជាណាចក្រកម្ពុជាពេលបច្ចុប្បន្ននេះ រាជរដ្ឋាភិបាលកំពុងតែធ្វើកំណែទម្រង់ប្រព័ន្ធច្បាប់ និងប្រព័ន្ធយុត្តិធម ។ សារណាមួយនេះត្រូវបានចាប់ស្រាវជ្រាវពីថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០១៦ ដល់ថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ ២០១៦ ។ ក្នុងរយៈពេលនេះខ្ញុំបាទបានប្រើប្រាស់ពេលវេលាក្នុងការស្វែងរកឯកសារដែលពាក់ព័ន្ធនឹងប្រធានបទ និងការពិគ្រោះយោបល់ជាមួយលោកគ្រូសាស្ត្រាចារ្យដើម្បីធ្វើឲ្យការរៀបចំតាក់តែងសារណាមួយនេះ ដែលអាចយកជាការបានទៅតាមពេលដែលបានកំណត់ និងទៅតាមទំហំនៃប្រធានបទ ។

ចុងបញ្ចប់ក្នុងនាម ខ្ញុំបាទជាអ្នករៀបរៀងនូវសារណាមួយនេះមានគោលបំណង និងសង្ឃឹមថាស្នាដៃមួយនេះនឹងក្លាយជាប្រយោជន៍ដល់ការសិក្សាស្រាវជ្រាវ និងជំនួយដល់ការពង្រីកចំណេះដឹងបន្ថែមដល់អ្នកដែលកំពុងសិក្សាទៅតាមតំរូវការរៀងៗខ្លួន ។

# មាតិកា

ទំព័រ

**សេចក្ដីផ្ដើម** ............................................................ ១

## ជំពូកទី១
## យុត្តិកម្មនៃបទល្មើស

**១.១. ការអនុញ្ញាតិដោយច្បាប់ ឬ អាជ្ញាធរ** ............................................................ ៦
១.១.១. ការអនុញ្ញាតិដោយច្បាប់ ............................................................ ៦
១.១.១.១. និយមន័យនៃច្បាប់ ............................................................ ៦
១.១.១.២. ករណីអនុវត្តជាក់ស្ដែង ............................................................ ៧
១.១.១.៣. ករណីមានការបញ្ញាត្តិ ឬ ការអនុញ្ញាតិដោយច្បាប់បរទេស ............................................................ ៧
១.១.២. ការអនុញ្ញាតិដោយអាជ្ញាធរ ............................................................ ៨
១.១.២.១. អាជ្ញាធរស្របច្បាប់ ............................................................ ៨
១.១.២.២. ការបញ្ជាស្របច្បាប់ ............................................................ ៨
១.១.៣. ការលើកលែង ឬ អញ្ញាត្រកម្ម ............................................................ ៩
**១.២. ការការពារជាធម្មានុរូប ឬ ការការពារស្របច្បាប់** ............................................................ ៩
១.២.១. លក្ខខណ្ឌនៃការការពារ ............................................................ ១០
១.២.១.១. ការឈ្លានពានមួយដែលមិនត្រឹមត្រូវ ............................................................ ១១
១.២.១.២. បទល្មើស និងការឈ្លានពានត្រូវកកើតឡើងក្នុងពេលតែមួយ ............................................................ ១១
១.២.១.៣. ភាពសមាមាត្ររវាងអំពើឈ្លានពាន និងការតបត ............................................................ ១២
១.២.២. ស្ថានភាពនៃការការពារ ............................................................ ១៣
១.២.២.១. ការការពារខ្លួន ............................................................ ១៤
១.២.២.២. ការការពារអ្នកដ៏ទៃ ............................................................ ១៤
១.២.២.៣. ការការពារទ្រព្យសម្បត្តិ ............................................................ ១៤
១.២.៣. សច្ចធារណ៍នៃការការពារស្របច្បាប់ ............................................................ ១៥
**១.៣. ស្ថានភាពចាំបាច់** ............................................................ ១៦
១.៣.១. គ្រោះថ្នាក់ដែលកំពុងកើត ឬ រៀបនឹងកើត ............................................................ ១៧
១.៣.១.១. គ្រោះថ្នាក់ដែលកំពុងកើត ............................................................ ១៧
១.៣.១.២. គ្រោះថ្នាក់ដែលរៀបនឹងកើត ............................................................ ១៧
១.៣.២. ការការពារជាចាំបាច់ ............................................................ ១៨
១.៣.៣. ភាពសមាមាត្ររវាងបធ្យោបាយការពារ និងទម្ងន់នៃគ្រោះថ្នាក់ ............................................................ ១៩

# ជំពូកទី២
# ភាពមិនអាចទម្លាក់កំហុសបាន

**២.១. វិបល្លាសស្មារតី** ........ ២០
២.១.១. និយមន័យ ........ ២០
២.១.២. លក្ខខណ្ឌដែលចាត់ទុកជាជនវិបល្លាសស្មារតី ........ ២១
២.១.៣. ករណីពិសេស ........ ២១
២.១.៣.១. វិបល្លាសស្មារតីពាក់កណ្ដាល ឬ បន្ថយការយល់ដឹង ........ ២១
២.១.៣.២. ការប្រើប្រាស់ថ្នាំ ........ ២១
២.១.៤. ការបង្ហាញភស្តុតាង ........ ២២
**២.២. អានុភាពនៃកម្លាំង ឬ ការបង្ខំ** ........ ២៣
២.២.១. និយមន័យ ........ ២៣
២.២.២. ប្រភេទនៃកម្លាំង ឬ ការបង្ខំ ........ ២៤
២.២.២.១. ការបង្ខំលើរូបរាងកាយ ........ ២៤
២.២.២.២. ការបង្ខំលើផ្លូវចិត្ត ........ ២៤
២.២.៣. លក្ខណៈនៃកម្លាំង និងការបង្ខំ ........ ២៥
២.២.៣.១. កម្លាំង និងការបង្ខំដែលមិនអាចមើលឃើញជាមុនបាន ........ ២៥
២.២.៣.២. កម្លាំង និងការបង្ខំដែលមិនអាចជៀសវាងបាន ........ ២៦
**២.៣. ករណីពិសេសចំពោះអនីតិជន** ........ ២៧
២.៣.១. អនីតិជនអាយុក្រោម ១៨ ឆ្នាំ ........ ២៧
២.៣.២. អនីតិជនអាយុក្រោម ១៤ ឆ្នាំ ........ ២៩

# ជំពូកទី៣
# បណ្ដាករណីដ៏ទៃផ្សេងទៀត

**៣.១. ការភាន់ច្រឡំ និងឥទ្ធិពលមៃការទទួលខុសត្រូវ** ........ ៣១
៣.១.១. ការភាន់ច្រឡំអំពីអង្គច្បាប់ ........ ៣១
៣.១.១.១. ការប្រព្រឹត្តអំពើដោយជាក់លាក់ ឬ ស្មាន ........ ៣១
៣.១.១.២. ការប្រព្រឹត្តអំពើយល់ច្រឡំ ........ ៣២
៣.១.២. ការភាន់ច្រឡំអំពីអង្គហេតុ ........ ៣២
៣.១.២.១. ការភាន់ច្រឡំកម្មវត្ថុ ........ ៣២
៣.១.២.២. ការភាន់ច្រឡំមុខសញ្ញា ........ ៣៣
៣.១.២.៣. ការភាន់ច្រឡំមធ្យោបាយ ........ ៣៤
៣.១.២.៤. ការភាន់ច្រឡំពីទំនាក់ទំនងហេតុផល ........ ៣៤
**៣.២. ផលប៉ះពាល់នៃផលិតកម្មស្រាវជ្រាវអំពីវិទ្យាសាស្ត្រ** ........ ៣៥
**៣.៣. ផលប៉ះពាល់នៃការអនុវត្តភារកិច្ចក្នុងមុខជំនាញ** ........ ៣៥

**៣.៤. ការយល់ពីសំណាក់ជនរងគ្រោះ** ........ ៣៦
    ៣.៤.១. ការព្រមព្រៀងពីជនរងគ្រោះ ........ ៣៦
    ៣.៤.២. ការបំពេញតាមសំណូមពរជនរងគ្រោះ ........ ៣៧
**សេចក្តីសន្និដ្ឋាន** ........ ៣៨
**អនុសាសន៍** ........ ៤០
**ឯកសារយោង**
**ឧបសម្ព័ន**

# សេចក្ដីផ្ដើម

មនុស្សគ្រប់រូបដែលមានវត្តមាន ហើយរស់នៅលើលោក យើងនេះសុទ្ធតែមានសិទ្ធិសេរីភាព និងត្រូវបានគ្រប់គ្រងដោយច្បាប់ដែលជាសញ្ជាតិរបស់ខ្លួន ។ ប្រជាពលរដ្ឋត្រូវបានទទួលស្គាល់ថាជាធាតុផ្សំមួយក្នុងចំនោមធាតុផ្សំទាំងបី នៃរដ្ឋព្រមទាំងមាននូវអធិបតេយ្យភាពផងដែរ។ ដូច្នេះហើយបានជារដ្ឋនីមួយៗ បានបង្កើតនូវនីតិពោល គឺច្បាប់តែម្ដង សម្រាប់គ្រប់គ្រងទៅលើប្រជាជនដែលកំពុងរស់នៅក្នុងប្រទេសរបស់ខ្លួន តួយ៉ាងដូចជា កម្ពុជាក៏បានបង្កើតច្បាប់សម្រាប់គ្រប់គ្រងរាល់ទំនាក់ទំនងទាំងអស់ក្នុងសង្គម មានដូចជាក្រមព្រហ្មទណ្ឌជាដើមដែលបង្កើតឡើងក្នុងគោលបំណងសំរាប់ការពារអាយុជីវិត កិត្តិយស សេចក្ដីថ្លៃថ្នូរ សិទ្ធិសេរីភាព និងទ្រព្យសម្បត្តិរបស់ប្រជាពលរដ្ឋរបស់ប្រជាពលរដ្ឋដែលកំពុងរស់នៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ។ ថ្វីត្បិតតែបែបនេះក្ដីក៏ប៉ុន្តែ សិទ្ធិសេរីភាពដែលពួកគេទទួលបានត្រូវបានជនមួយចំនួនបានយកសិទ្ធិនោះទៅបង្កគ្រោះថ្នាក់ដល់អាយុជីវិត និងគំរាមគំហែងដល់បូរណភាពរូបរាងកាយ ឬ បូរណភាពផ្លូវចិត្តព្រមទាំងប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ទំនាក់ទំនងសង្គមផងដែរ ហើយដែលក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាយើងចាត់ទុកជាបទល្មើស។ ក្នុងទិដ្ឋភាពជាក់ស្ដែងក្នុងសង្គមកម្ពុជានាពេលបច្ចុប្បន្នបណ្ដាលឲ្យមានអំពើតបទល់ ឬ ការការពារខ្លួនមួយចំនួនក្នុងស្ថានភាពចាំបាច់ និងរូបភាពខាងក្រៅដែលមានភាពដូចគ្នាទៅនឹងបទល្មើសដែលក្រមព្រហ្មទណ្ឌបានបញ្ញត្តិ ប៉ុន្តែអំពើទាំងនោះត្រូវបានបំពេញទៅតាមលក្ខខណ្ឌដែលក្រមព្រហ្មទណ្ឌទទួលស្គាល់ថា ជាអំពើដែលមានប្រយោជន៍ដល់សង្គម ហើយវានាំឲ្យអ្នកប្រព្រឹត្តនោះរួចផុតពីការទទួលខុសត្រូវខាងផ្នែកព្រហ្មទណ្ឌ។

អាស្រ័យដូចបានរៀបរាប់ខាងលើនេះទើប ខ្ញុំបាទដែលជានិស្សិតថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រ ជំនាន់ទី១៦ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច បានខិតខំប្រឹងប្រែង និងស្រាវជ្រាវនូវសារណាមួយនេះឡើងក្រោមប្រធានបទ **មូលហេតុដែលរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌ** ដើម្បីជាការចំនួនដល់ការសិក្សាស្រាវជ្រាវរបស់អ្នកសិក្សាទាំងឡាយ និងមិត្តនិស្សិតទាំងអស់ដែលមានបំណងចង់បំពេញចំណេះដឹងបន្ថែម ទៅលើការសិក្សាស្រាវជ្រាវដែលពាក់ព័ន្ធនឹងប្រធានបទនេះក៏ដូចជាសិក្សាទៅលើជ្រុងមួយនៃក្រមព្រហ្មទណ្ឌ ។ ម៉្យាងទៀតក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាដែលទើបតែបង្កើតបានប៉ុន្មានឆ្នាំកន្លងទៅនេះ ក៏នៅតែមានប្រជាពលរដ្ឋក៏ដូចជាអ្នកសិក្សាមួយចំនួនពុំទាន់យល់ជ្រាប និងនូវតែជាបញ្ហាចម្ងល់ស្រពេចស្រពិលនៅឡើយ ដូច្នេះមូលហេតុដែលរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌនឹងជាចំណែកមួយដ៏សំខាន់សម្រាប់ពួកគាត់ និងកំណត់ឲ្យច្បាស់នូវការការពារទំនាក់ទំនងទាំងអស់ដែលអាចបង្កឲ្យមានការអន្តរាយ ភាពអនាធិបតេយ្យ បាត់បង់សណ្ដាប់ធ្នាប់ ប្រពៃណីដ៏ល្អផូរផង់ ប៉ះពាល់ដល់ទំនាក់ទំនងល្អដែលបង្កឡើងដោយជនខិលខូចមួយចំនួន និងដើម្បីធានាឲ្យបាននូវការអនុវត្តច្បាប់ឲ្យក្លាយជា

ប្រទេសនីតិរដ្ឋពិតប្រាកដ ។ ក្រមព្រហ្មទណ្ឌនៃព្រះរាជាចក្រកម្ពុជាបានបញ្ញត្តិស្តីពីការទទួលខុសត្រូវ និងការមិនអាចទម្លាក់កំហុសបាន ព្រមទាំងទ្រឹស្តីមួយចំនួន ដែលពាក់ព័ន្ធទៅនឹងការអនុវត្តជាប្រចាំក្នុងជីវភាពរបស់ប្រជាពលរដ្ឋក្នុងពេលបច្ចុប្បន្ននេះ។

សារណាក្រោមប្រធានបទ មូលហេតុដែលរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌ នេះត្រូវបានកំណត់សរសេរដោយផ្អែកតាម ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩។

## ១.ចំនោទបញ្ហានៃការស្រាវជ្រាវ

ដើម្បីជាជំនួយ និងជាភាពងាយស្រួលក្នុងការបកស្រាយនូវប្រធានបទមួយនេះ ខ្ញុំបាទសូមធ្វើការលើកយកនូវចំនោទបញ្ហាដែលពាក់ព័ន្ធ មូលហេតុដែលរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌ មកធ្វើការចោទសួរដូចតទៅ៖

- តើមូលហេតុអ្វីខ្លះដែលចាត់ទុកជាមូលហេតុដែលរួចផុតពីការទទួលខុសត្រូវ។
- តើអំពើតបត និងលក្ខខណ្ឌដែលច្បាប់បានកំណត់មានលក្ខណៈបែបណាខ្លះ ចំពោះការរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌ។
- រីឯការអនុវត្តជាក់ស្តែងវិញមានលក្ខណៈបែបណា។
- ចុះចំណែកអនីតិជន តើក្រមព្រហ្មទណ្ឌបានកំណត់ពីការរួចផុតពីការទទួលខុសត្រូវដែរ ឬទេ។

## ២.គោលបំណងនៃការស្រាវជ្រាវ

ការសម្រេចចិត្តជ្រើសរើសប្រធានបទនេះមកសរសេរ ពីព្រោះខ្ញុំបាទមានបំណងចង់បង្ហាញថាប្រធានបទមួយនេះពិតជាមានសារៈសំខាន់ចំពោះប្រជាពលរដ្ឋ ព្រមទាំងអ្នកសិក្សាផ្នែកនីតិសាស្ត្រ អ្នកប្រកបវិជ្ជាជីវៈច្បាប់គ្រប់រូប ជាពិសេស នីតិជន និងជាអនីតិជនដែលស្ថិតនៅក្រោមការទទួលខុសត្រូវព្រហ្មទណ្ឌ ក្នុងគោលបំណងរួមចំណែកជំនួយស្មារតីក្នុងការគោរព និងការពារអាយុជីវិត សិទ្ធិសេរីភាព ព្រមទាំងទ្រព្យសម្បត្តិខ្លួនឯងក៏ដូចជាទ្រព្យសម្បត្តិរបស់អ្នកដ៏ទៃ។

## ៣.ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ដែនកំណត់នៃប្រធានបទនេះ លាតសន្ធឹងដល់ការរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌនៅព្រះរាជាចក្រកម្ពុជាពីឆ្នាំ ១៩៦៩ ដល់ បច្ចុប្បន្ន ។

## ៤.សារៈសំខាន់នៃការស្រាវជ្រាវ

ការជ្រើសរើសយកនូវប្រធានបទនេះមកធ្វើការស្រាវជ្រាវ ពីព្រោះខ្ញុំបាទចង់ស្វែងយល់ឲ្យកាន់តែច្បាស់ និងស៊ីជម្រៅអំពីអត្ថន័យនៃការទទួលខុសត្រូវព្រហ្មទណ្ឌ ក៏ដូចជាមាននូវលក្ខខណ្ឌក្នុងការទទួលបាននូវការរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌដែលច្បាប់ផ្តល់ឲ្យ ។ រីឯសារៈសំខាន់នៃប្រធាននេះគឺ ខ្ញុំបាទចង់បង្ហាញពីគោលការណ៍នៃក្រមព្រហ្មទណ្ឌដែលកំពុងអនុវត្ត និងកំពុងនៅ

ជាធរមានដើម្បីផ្តល់ការងាយស្រួលដល់ការសិក្សានីតិព្រហ្មទណ្ឌ ជាពិសេសនោះគឺក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩ តែម្តង ។

## ៥.វិធីសាស្ត្រស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវជាចម្បងនៃប្រធានបទនេះ គឺត្រូវចេះផ្តោតសំខាន់ទៅលើបណ្តាឯកសារទាំងឡាយណាដែលពាក់ព័ន្ធ ទៅនឹងរាល់មូលហេតុដែលនាំឲ្យរួចផុតពីការទទួលខុសត្រូវរវាងទំហំនៃការឈ្លានពាន និងកម្លាំងនៃការតបត។

លំដាប់នៃការស្រាវជ្រាវ គឺជាការជ្រើសរើសប្រធានបទ ការកំណត់បញ្ហា ការកំណត់ពីគោលដៅក្នុងការស្រាវជ្រាវ ការរៀបចំ និង ប្រមូលឯកសារពាក់ព័ន្ធ ការសរសេរកិច្ចការ និងការធ្វើសេចក្តីសន្និដ្ឋាន។

គោលដៅ និងកម្មវត្ថុនៃការស្រាវជ្រាវ គឺសំដៅទៅដល់បណ្តាមូលហេតុទាំងអស់ដែលច្បាប់ចាត់ទុកថាមិនមែនជាបទល្មើស និងភាពមិនអាចទម្លាក់កំហុសបានបន្ថែមដោយករណីផ្សេងទៀតដែលតែងតែជួបប្រទះក្នុងជីវភាពរស់នៅប្រចាំថ្ងៃ។

ការរៀបចំ និងការប្រមូលឯកសារពាក់ព័ន្ធគឺៈ

- រាល់បណ្តាឯកសារទាំងអស់ ដែលប្រមូលបានរៀបតាមលំដាប់លំដោយ ដើម្បីជាការងាយស្រួលដល់ការសរសេរ ជៀសវាងការចំណាយពេលវេលាច្រើន។
- ការរៀបចំឯកសារទាំងអស់ទៅតាមចំណាត់ថ្នាក់នៃជំពូកនីមួយៗ។
- ការប្រមូលទិន្នន័យដោយធ្វើតាមវិធីស្រាវជ្រាវ ការប្រើប្រាស់សំណួរជាគន្លឹះ និងវិភាគឲ្យស៊ីជម្រៅនៃប្រធានបទ។
- ជាចុងក្រោយគឺ កត់ត្រានូវរាល់ចំនុចសំខាន់ៗ ដើម្បីផ្តាល់ការងាយស្រួលចំណាំពេលប្រើប្រាស់ការសម្គាល់ក្រោមទំព័រ (Footnote)។

## ៦.រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

សារណាបញ្ចប់ការសិក្សានេះសរុបមានចំនួន ៩០ ទំព័រ និងត្រូវបានបែងចែកជា ៣ជំពូកគឺ: ជំពូកទី ១ យុត្តិកម្មនៃបទល្មើស ជំពូកទី ២ ភាពមិនអាចទម្លាក់កំហុសបាន និងជំពូកទី ៣ បណ្តាករណីដទៃផ្សេងទៀត។

ជំពូកទី ១ បង្ហាញពីយុត្តិកម្មនៃបទល្មើសដែលក្នុងនោះរួមមាន ការអនុញ្ញាតិដោយច្បាប់ ឬដោយអាជ្ញាធរ ការការពារស្របច្បាប់ និងស្ថានភាពចាំបាច់។

ជំពូកទី ២ បង្ហាញពីភាពមិនអាចទម្លាក់កំហុសបានដែលក្នុងនោះរួមមាន វិបល្លាសស្មារតី អនុភាពនៃកម្លាំង ឬការបង្ខំ និងករណីពិសេសចំពោះអនីតិជន។

ជំពូកទី ៣ បង្ហាញពីបណ្ដាករណីផ្សេងទៀត ដែលក្នុងនោះរួមមាន ការភាន់ច្រឡំ ឥទ្ធិពលនៃការទទួលខុសត្រូវ ផលប៉ះពាល់នៃផលិតកម្មស្រាវជ្រាវអំពីវិទ្យាសាស្ត្រ ផលប៉ះពាល់នៃការអនុវត្តភារកិច្ចក្នុងមុខជំនាញ ការព្រមព្រៀងពីជនរងគ្រោះ និងការបំពេញតាមសំណូមពរ ជនរងគ្រោះ។

# ជំពូកទី ១
# យុត្តិកម្មនៃបទល្មើស

គ្រប់ទំនាក់ទំនងទាំងអស់របស់មនុស្ស នៅក្នុងសង្គមនៃ ក្រុម រដ្ឋ ឬ ប្រទេសណាមួយសុទ្ធតែត្រូវបានគ្រប់គ្រងដោយច្បាប់ និងបទដ្ឋានគតិយុត្តនៃប្រទេស ឬ រដ្ឋមួយនោះ។ ក្រោមលក្ខខណ្ឌទាំងអស់នេះមិនមែនមានន័យថា គ្រប់អំពើទាំងអស់ដែលច្បាប់បានកំណត់ថាវា ជាបទល្មើសសុទ្ធតែជាបទល្មើសទាំងអស់នោះទេ ពីព្រោះថាអំពើខ្លះត្រូវបានកើតឡើងដោយសារការអនុវត្តសិទ្ធិ ឬ ការអនុវត្តកាតព្វកិច្ច ហើយទំហំនៃផលប្រយោជន៍គឺត្រូវស្របទៅនឹងច្បាប់។ ដូច្នេះ ប្រសិនបើច្បាប់បានអនុញ្ញាតឲ្យធ្វើសកម្មភាពនោះមិនត្រូវចាត់ទុកជាបទល្មើសព្រហ្មទណ្ឌទេ។ ពាក្យថា **យុត្តិកម្មនៃបទល្មើស** នេះគួបផ្សំឡើងដោយពាក្យជាច្រើនរួមបញ្ចូលគ្នា គឺ៖

- **យុត្តិ** គឺ សេចក្តីត្រូវការ ទៀងត្រង់ ការគួរតាមច្បាប់[1]
- **កម្ម** គឺ សំដៅដល់អំពើ ទោះអំពើល្អក្តី អាក្រក់ក្តី ក៏ហៅថាអំពើ[2]

**យុត្តិកម្ម** គឺ ការរកឃើញខុសត្រូវ ឲ្យឃើញយុត្តិធម៌ចំពោះអំពើណាមួយ[3]

**បទល្មើស** គឺជាអំពើប្រឆាំងទៅនឹងរដ្ឋ, អំពើដែលនាំឲ្យមានគ្រោះថ្នាក់ដល់សង្គម, អំពើប្រឆាំងទៅនឹងច្បាប់ជាធរមាន ដែលមានចែងក្នុងច្បាប់ព្រហ្មទណ្ឌនឹងត្រូវផ្តន្ទាទោសក្នុងបទឧក្រិដ្ឋ បទមជ្ឈិម និងបទលហុ។[4]

**បទល្មើស** គឺជាអំពើរបស់មនុស្ស ហើយអំពើនេះបានផ្ទុកនូវចរិតគ្រោះថ្នាក់ដល់សង្គម ដែលវាស្តែងឡើងនៅត្រង់ចំនុច អំពើបានបង្កអន្តរាយ ឬ ការគម្រាមកំហែងឲ្យមានអន្តរាយដល់បណ្តាប្រយោជន៍ដែលច្បាប់បានការពារ។[5]

ដោយបានបង្ហាញឡើងនូវពាក្យដូចខាងលើយើងអាចធ្វើការសន្និដ្ឋានបានថា **យុត្តិកម្មនៃបទល្មើស** គឺជាអំពើដែលកើតមានឡើងក្នុងស្ថានភាពដ៏ចាំបាច់មួយ ដែលបុគ្គលជាជនរងគ្រោះបានរងនូវអំពើបំពានពីប្រធាននៃបទល្មើស ហើយដែលរាល់អំពើដែលបានល្មើសទាំងអស់នោះ ត្រូវបានរកឃើញថាជាអំពើដែលបានបង្កឡើងពីភាគីដែលជាជនល្មើស ហើយនឹងស្ថិតនៅក្នុងកាលៈទេសៈណាមួយដែលភាគីជាជនរងគ្រោះពុំអាចបញ្ចៀសនូវគ្រោះថ្នាក់នោះបាន ក៏ខ្លួនត្រូវតែប្រើសិទ្ធរបស់ខ្លួននូវក្នុងការ

[1] សម្តេចព្រះសង្ឃរាជ ជួន ណាត វចនានុក្រមខ្មែរ (ភ្នំពេញ៖ វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ, ព.ស.២៥១១ គ.ស១៩៦៧)

[2] សម្តេចព្រះសង្ឃរាជ ជួន ណាត វចនានុក្រមខ្មែរ (ភ្នំពេញ៖ វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ, ព.ស.២៥១១ គ.ស១៩៦៧)

[3] វចនានុក្រមខ្មែរ អង់គ្លេស, អង់គ្លេស ខ្មែរ បោះពុម្ពលើកទី១ ឆ្នាំ២០១២ រក្សាសិទ្ធ ដោយ ហ៊ីង ធីឫទ្ធិ (របស់លោក ភូ ឡាយស៊ុន និងលោក ភូ រួចចេង)

[4] វចនានុក្រមខ្មែរ អង់គ្លេស, អង់គ្លេស ខ្មែរ បោះពុម្ពលើកទី១ ឆ្នាំ២០១២ រក្សាសិទ្ធ ដោយ ហ៊ីង ធីឫទ្ធិ (របស់លោក ភូ ឡាយស៊ុន និងលោក ភូ រួចចេង)

[5] ជួន ប៊ុនធី, នីតិព្រហ្មទណ្ឌទូទៅ

ការពារ ប្រឆាំងតបត និងធ្វើការទប់ទល់ទៅនឹងអំពើបំពានដែលធ្លាក់មកលើខ្លួន ដើម្បីធ្វើការការពារខ្លួន ការពារសិទ្ធិរបស់ខ្លួន ឬ អ្នកដទៃ ឬ ការពារផលប្រយោជន៍ទ្រព្យសម្បត្តិសាធារណៈដែលច្បាប់បាន អនុញ្ញាតឲ្យប្រើប្រាស់សិទ្ធក្នុងការទប់ទល់។ ប៉ុន្តែពាក្យថា **យុត្តិកម្មនៃបទល្មើស** គឺគ្រាន់តែជាការ លើកយកមកសិក្សាដើម្បីជាគំនិតបន្ថែមដល់អ្នកសិក្សាប៉ុណ្ណោះព្រោះថានៅក្នុងក្រមព្រហ្មទណ្ឌ នៃ ព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៩ ថ្មី មិនបានប្រើពាក្យ **យុត្តិកម្មនៃបទល្មើស** ទេគ្រាន់តែកំណត់ ៣ ករណីថាជាមូលហេតុនៃការរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌដែលរួមមានការអនុញ្ញាតដោយ ច្បាប់ ឬ អាជ្ញាធរ (១.១) ការការពារស្របច្បាប់ (១.២) និងស្ថានភាពចាំបាច់ (១.៣)។

## ១.១ ការអនុញ្ញាតដោយច្បាប់ ឬដោយអាជ្ញាធរ

**បុគ្គលណាដែលបានប្រព្រឹត្តអំពើដែលបានបញ្ញត្តិ ឬ អនុញ្ញាតតាមច្បាប់ បុគ្គលនោះមិនប្រព្រឹត្ត បទល្មើសទេ។ បុគ្គលណាដែលប្រព្រឹត្តអំពើតាមបទបញ្ជារបស់អាជ្ញាធរស្របច្បាប់ បុគ្គលនោះមិន ប្រព្រឹត្តបទល្មើសទេ លើកលែងតែអំពើនេះជាអំពើខុសច្បាប់យ៉ាងជាក់ច្បាស់។**[6]

យោងតាមអត្ថន័យខាងលើនេះ ក្រមព្រហ្មទណ្ឌរបស់យើងបានបង្ហាញថាអំពើនោះ ត្រូវបាន បញ្ញត្តិថាជាបទល្មើស ប៉ុន្តែបែរជាមិនមែនជាបទល្មើសទៅវិញ ដោយសារតែអំពើនោះត្រូវបាន អនុញ្ញាតដោយច្បាប់ និងដោយមានការអនុញ្ញាតពីអាជ្ញាធរ។

### ១.១.១ ការអនុញ្ញាតដោយច្បាប់

រាល់អំពើទាំងឡាយណាដែលកើតចេញពីការបំពេញកាតព្វកិច្ច ដែលតំរូវដោយច្បាប់ ឬ ជា ការអនុវត្តសិទ្ធិដែលច្បាប់បានបញ្ញត្តិ ឬ អនុញ្ញាតឲ្យប្រព្រឹត្តអំពើនោះច្បាប់មិនបានបញ្ញត្តិឲ្យផ្តន្ទា ទោសឡើយចុះពាក្យថាច្បាប់ ក្នុងមាត្រាខាងលើមានន័យយ៉ាងដូចម្តេច? ន័យទូលាយ ឬ ន័យ ចង្អៀត?

#### ១.១.១.១ និយមន័យនៃច្បាប់[7]

**ន័យទូលាយ:** សំដៅលើរាល់លិខិតបទដ្ឋានគតិយុត្តដែលត្រូវបានបង្កើត និងគ្រប់គ្រង ទំនាក់ទំនងទាំងអស់ក្នុងសង្គម។

**ន័យចង្អៀត:** សំដៅលើរាល់លិខិតបទដ្ឋានគតិយុត្តដែលត្រូវបានបង្កើត និងអនុម័តឡើង ដោយអង្គការនីតិបញ្ញត្តិ និងឡាយព្រះហត្ថលេខាដាក់ឲ្យប្រើប្រាស់ដោយព្រះមហាក្សត្រ។

យោងតាមរយៈនិយមន័យទាំងពីរខាងលើ ក្រមព្រហ្មទណ្ឌមិនបានបញ្ញត្តិថាជាច្បាប់ក្នុងន័យ មួយណានោះទេ ប៉ុន្តែយ៉ាងណាមិញបើយើងសង្កេតមើលទៅ ប្រសិនបើមានករណីមួយដែលអាច ចាត់ទុកជាករណីដែលរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌ លុះត្រាតែមានការអនុញ្ញាតពីច្បាប់ ឬ

[6] មាត្រា៣២ ក្រមព្រហ្មទណ្ឌនៃព្រះរាជាចក្រកម្ពុជាឆ្នាំ ២០០៩ .នស/រកម/១១០៩/០២២. ៣០ វិច្ឆិកា ២០០៩

[7] សេចក្តីផ្តើមនីតិកម្ពុជា ក្រោមការដឹកនាំដោយការិយាល័យស្រាវជ្រាវរបស់ ស.ភ.ន.វ.ស

មាននៅក្នុងបញ្ញត្តិច្បាប់ (ន័យចង្អៀត) ទើបករណីនោះក្លាយជាមូលហេតុដែលរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌ។

**ឧទាហរណ៍:** **១.** ការចាប់ខ្លួនជនសង្ស័យដែលធ្វើឡើងដោយមន្ត្រីនគរបាលយុត្តិធម៌ ចំពោះបទល្មើសជាក់ស្តែង[8]។ ការចាប់ខ្លួនជនសង្ស័យស្ថានភាពជាក់ស្តែងគឺ ត្រូវបានក្រមព្រហ្មទណ្ឌកំណត់ពីអំណាចរបស់មន្ត្រីនគរបាលយុត្តិធម៌ ទៅតាមក្របខណ្ឌនៃការស៊ើបអង្កេតករណីជាក់ស្តែង។

**២.** ការចាប់ខ្លួនជនល្មើសដែលធ្វើឡើងដោយប្រជាពលរដ្ឋក្នុងករណីដែលបទឧក្រិដ្ឋ ឬ បទមជ្ឈិមជាក់ស្តែង[9]។ ការចាប់ខ្លួនជនល្មើសដែលបានប្រព្រឹត្តជាក់ស្តែងបែបនេះគឺ មិនអាចចាត់ទុកថាជាបទល្មើសឡើយ។

ឧទាហរណ៍ខាងលើ បង្ហាញឲ្យយើងឃើញថា ក្រមនីតិវិធីព្រហ្មទណ្ឌបានអនុញ្ញាតឲ្យមន្ត្រីនគរបាលយុត្តិធម៌បំពេញភារៈកិច្ចរបស់ខ្លួនទៅតាមក្របខណ្ឌនៃមុខងារដែលច្បាប់បានកំណត់ និងអនុញ្ញាត គឺបានន័យថាមិនមានទោស និងមិនមែនជាបទល្មើសឡើយ រីឯការចាប់ខ្លួនជនល្មើសដែលធ្វើឡើងដោយប្រជាពលរដ្ឋ ក៏មិនមែនជាបទល្មើសដែរ ពីព្រោះការចាប់ខ្លួននេះត្រូវបានអនុញ្ញាតដោយច្បាប់ពោលគឺ ក្រមនីតិវិធីព្រហ្មទណ្ឌតែម្តង។

### ១.១.១.២ ករណីការអនុវត្តជាក់ស្តែង

ចំពោះការអនុវត្តជាក់ស្តែងក៏ដូចជា ទំនៀមទំលាប់មួយចំនួនវិញត្រូវបានលើកលែងដោយមិនត្រូវបានទទួលខុសត្រូវព្រហ្មទណ្ឌឡើយ។ **ឧទាហរណ៍:** ក្នុងវិស័យកីឡា ដូចជាកីឡាប្រដាល់យូដូជាដើម កីឡាប្រភេទនេះអាចបង្កឲ្យប៉ះពាល់ដល់បូរណភាពរូបរាងកាយរបស់ភាគី ក៏មិនត្រូវទទួលខុសត្រូវព្រហ្មទណ្ឌដែរ ដោយតម្រូវឲ្យកីឡាករទាំងអស់ត្រូវអនុវត្តតាមបទបញ្ជាកីឡានោះឲ្យបានត្រឹមត្រូវទើបរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌ នៅពេលមានឧប្បត្តិហេតុកើតឡើង។ ផ្ទុយទៅវិញបើមិនគោរពបទបញ្ជារបស់កីឡាយូដូនេះទេ គឺត្រូវទទួលខុសត្រូវព្រហ្មទណ្ឌដោយចៀសមិនផុតឡើយ។ ករណីខាងលើនេះគេច្រើនតែយកមកធ្វើជាមូលហេតុនៃការរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌ ដោយសំអាងថាជា ទំនៀមទម្លាប់ដែលគេតែងតែអនុវត្តតាំងពីយូណាស់មកហើយ ទោះបីជាគ្មានបទដ្ឋានគតិយុត្ត ឬ ច្បាប់ណាមួយបញ្ញត្តិ ឬ អនុញ្ញាតក៏ដោយ។

### ១.១.១.៣ ករណីមានការបញ្ញត្តិ ឬការអនុញ្ញាតដោយច្បាប់បរទេស

ជាទូទៅច្បាប់បរទេស ឬ សាលក្រមស្ថាពររបស់តុលាការបរទេស មិនមានអនុភាពអនុវត្តដោយផ្ទាល់ឡើយនៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជាឡើយ។ ដូច្នេះការបញ្ញត្តិ ឬ ការអនុវត្ត

[8] មាត្រា ៨៥. ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា. នស/រកម/០៨០៧/០២៤. ១០ សីហា ២០០៧

[9] មាត្រា ៨៧. ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា. នស/រកម/០៨០៧/០២៤. ១០ សីហា ២០០៧

ច្បាប់បរទេស មិនអាចចាត់ទុកជាមូលហេតុនៃការរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌបានឡើយ។ លុះត្រាតែបានបំពេញលក្ខខណ្ឌដែលបានកំណត់ក្នុងក្រមនីតិវិធីរដ្ឋប្បវេណី[10]។

**១.១.២ ការអនុញ្ញាតដោយអាជ្ញាធរ**

បុគ្គលណាដែលបានប្រព្រឹត្តអំពើតាមបទបញ្ជារបស់អាជ្ញាធរស្របច្បាប់ បុគ្គលនោះមិនប្រព្រឹត្តបទល្មើសទេ លើកលែងតែអំពើនោះជាអំពើខុសច្បាប់[11]។ ការបញ្ជារបស់អាជ្ញាធរ គឺត្រូវបានចាត់ទុកថាជាមូលហេតុនៃការរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌ ប៉ុន្តែចាំបាច់ត្រូវតែជាអាជ្ញាធរស្របច្បាប់ ឬ ជាបទបញ្ជាស្របច្បាប់។

**១.១.២.១ អាជ្ញាធរស្របច្បាប់**

អាជ្ញាធរស្របច្បាប់នោះ គឺសំដៅទៅលើអាជ្ញាធរសាធារណៈ ដែលមានអំណាចតាមផ្លូវច្បាប់ក្នុងការបញ្ជាឲ្យអនុវត្តច្បាប់ដូចជា អាជ្ញាធររដ្ឋបាល អាជ្ញាធរតុលាការជាដើម។ តាមអត្ថន័យខាងលើមិនបានចាត់ទុកថា ការបញ្ជារបស់ឪពុក ម្ដាយ ឬ និយោជកជាការបញ្ជាស្របច្បាប់នោះទេ ក្នុងករណីដែលឪពុក ម្ដាយ ឬ និយោជកបញ្ជាឲ្យនិយោជិត ឬ កូនរបស់ខ្លួនប្រព្រឹត្តអំពើណាមួយផ្ទុយនឹងច្បាប់ ជាការបញ្ជាស្របច្បាប់ឡើយ។ **ឧទាហរណ៍:** ប្រធានក្រុមហ៊ុន A បានបញ្ជាឲ្យកម្មករនិយោជិតរបស់ខ្លួនលួចឯកសារក្រុមហ៊ុន B ដែលនេះវាជាអំពើផ្ទុយនឹងច្បាប់។ ការបញ្ជារបស់ប្រធានក្រុមហ៊ុន A នេះគឺជាអំពើល្មើសនឹងច្បាប់ ហើយត្រូវបានចាត់ទុកថាជាមូលហេតុដែលនាំឲ្យអំពើនោះមិនស្របច្បាប់។ **ឧទាហរណ៍:** ឪពុកម្ដាយរបស់ឈ្មោះ ក បានបញ្ជាឲ្យកូនរបស់គាត់ប្រព្រឹត្តអំពើណាមួយផ្ទុយនឹងច្បាប់ ដូច្នេះបទបញ្ជាមួយនេះក៏មិនត្រូវបានចាត់ទុកជាមូលហេតុស្របច្បាប់នោះដែរ។

**១.១.២.២ ការបញ្ជាស្របច្បាប់**

ការបញ្ជាដែលមានលក្ខណៈខុសច្បាប់យ៉ាងជាក់ច្បាស់ គឺជាបញ្ជាអង្គហេតុដែលក្រមព្រហ្មទណ្ឌតំរូវឲ្យអ្នកទទួលបញ្ជាអនីត្យានុកូលនោះ ទទួលទោសតាមបញ្ញត្តិច្បាប់ដោយប្រកែកមិនបាន ដូច្នេះការវាយតម្លៃ និងកំណត់ថាបទបញ្ជានោះមានលក្ខណៈខុសច្បាប់ត្រូវពិនិត្យមើលលើស្ថានភាពជាក់ស្តែងរបស់អ្នកទទួលបញ្ជាដូចជា សមត្ថភាព បទពិសោធន៍ និងឋានៈជាដើម។ **ឧទាហរណ៍:** ១. មន្ត្រីសាធារណៈដែលមានឋានន្តរសក្តិខ្ពស់ អាចមានសមត្ថភាព វាយតម្លៃពីការដាក់បញ្ជារបស់ថ្នាក់លើខ្លួន ជាងមន្ត្រីសាធារណៈដែលមានឋានន្តរសក្តិទាប ឬ ប្រជាពលរដ្ឋធម្មតានៅពេលដែលអាជ្ញាធរបញ្ជាឲ្យធ្វើអ្វីមួយ។ **ឧទាហរណ៍:** ២. ការបញ្ជាឲ្យធ្វើទារុណកម្មទៅលើជន

[10] មាត្រា ១៩៩. ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា. នស/រកម/០៧០៦/០២១. ០៦ កក្កដា ២០០៦

[11] មាត្រា ៣២. ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា. នស/រកម/១១០៩/០២២. ៣០ វិច្ឆិកា ២០០៩

សង្ស័យពេលសួរចម្លើយ ។ ករណីនេះបើបទបញ្ជានេះត្រូវបានអនុវត្តនោះអ្នកអនុវត្តពុំអាចរួចផុតពីការទទួលខុសត្រូវបានឡើយ។

សរុបសេចក្តីមក ដើម្បីរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌ លុះត្រាតែបានបំពេញនូវគ្រប់លក្ខខណ្ឌដែលបានបញ្ញត្តិ ឬអនុញ្ញាតឲ្យធ្វើអំពើនោះដោយអនុលោមទៅតាមក្រមព្រហ្មទណ្ឌ។

### ១.១.៣ ការលើកលែង ឬអញ្ញត្រកម្ម

ចារី សហចារី ឬអ្នកផ្សំគំនិត ក្នុងបទប្រល័យពូជសាសន៍ បទឧក្រិដ្ឋប្រឆាំមនុស្សជាតិ ឬ បទឧក្រិដ្ឋសង្គ្រាមមិនអាចលើកលែងឲ្យផុតពី ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ខ្លួនទេទោះបីក្នុងករណីមានមូលហេតុដូចខាងក្រោមក៏ដោយ៖

១.ជនល្មើសដែលបានប្រព្រឹត្តអំពើដែលបញ្ញត្តិ អនុញ្ញាត ឬមិនហាមឃាត់ជនល្មើសនោះដោយច្បាប់ជាធរមាន។

២.បុគ្គលនោះបានប្រព្រឹត្តតាមបញ្ជារបស់អាជ្ញាធរស្របច្បាប់[12]។

**ឧទាហរណ៍:** ទោះបីជាច្បាប់ជាធរមាននៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យអនុញ្ញាតឲ្យមានការសម្លាប់មនុស្សក៏ដោយ ក៏អំពើនោះត្រូវបានចាត់ទុកជា បទឧក្រិដ្ឋប្រល័យពូជសាសន៍[13]បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ[14]បទឧក្រិដ្ឋសង្គ្រាម[15] ដូច្នេះ ចារី សហចារី អ្នកផ្តើមគំនិត ឬអ្នកផ្សំគំនិតមិនអាចរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌបានឡើយ ទោះបីជាជនល្មើសបានប្រព្រឹត្តអំពើដែលច្បាប់នាសម័យនោះបានបញ្ញត្តិអនុញ្ញាត ឬច្បាប់មិនបានហាមឃាត់ក៏ដោយ។

## ១.២ ការការពារជាធម្មានុរូប ឬ ការការពារស្របច្បាប់

ការការពារជាធម្មានុរូប ឬ ការការពារស្របច្បាប់ គឺមានលក្ខណៈនៃការពន្យល់ខុសគ្នាដូចខាងក្រោម៖

- ការការពារជាធម្មានុរូប ឬ ការការពារស្របច្បាប់ គឺជាអំពើរបស់មនុស្សម្នាក់ ដើម្បីការពារផលប្រយោជន៍របស់រដ្ឋ របស់សង្គម ផលប្រយោជន៍ស្របច្បាប់របស់ខ្លួន ឬ របស់អ្នកដទៃ បានតបទល់ដោយស្របជាមួយនឹងជនដែលកំពុងប្រព្រឹត្តអំពើរំលោភបំពាន លើផលប្រយោជន៍ណាមួយក្នុងចំណោមផលប្រយោជន៍ខាងលើ ហើយការការពារបែបនេះមិនត្រូវបានចាត់ទុកថាជាបទល្មើសឡើយ។

[12] មាត្រា ៣២. ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា. នស/រកម/១១០៩/០២២. ៣០ វិច្ឆិកា ២០០៩

[13] មាត្រា ១៨៣. ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា. នស/រកម/១១០៩/០២២. ៣០ វិច្ឆិកា ២០០៩

[14] មាត្រា ១៨៨. ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា. នស/រកម/១១០៩/០២២. ៣០ វិច្ឆិកា ២០០៩

[15] មាត្រា ១៩៣. ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា. នស/រកម/១១០៩/០២២. ៣០ វិច្ឆិកា ២០០៩

• ការការពារជាធម្មានុរូប ឬ ការការពារស្របច្បាប់ គឺជាការការពារខ្លួនឯង ឬ ការពារជនដទៃ ទល់នឹងការវាយប្រហារមុន ឬ ជិតមកដល់ និងដោយច្បាប់របស់ជនបំពាន។ ការការពារបែបនោះត្រូវតែមានហេតុផលបញ្ជាក់ ហើយវានឹងមិននាំឲ្យមានការទទួលខុសត្រូវពីសំណាក់អ្នកការពារសិទ្ធិ ដោយហេតុផលថា មានការចាំបាច់ត្រូវរុញច្រានការប្រើកំលាំងមិនស្របច្បាប់របស់ជនបំពាននោះ។[16]

ដោយហេតុថាការការពារជាធម្មានុរូប ឬ ការការពារស្របច្បាប់ គឺជាសិទ្ធិរបស់ជនគ្រប់រូប ដូចនេះបុគ្គលណាដែលបានប្រព្រឹត្តបទល្មើសក្នុងសភាពការពារស្របច្បាប់ មិនទទួលខុសត្រូវព្រហ្មទណ្ឌទេ ។ ប៉ុន្តែយ៉ាងណាមិញបុគ្គលម្នាក់ៗ អាចប្រប្រាស់សិទ្ធិនេះដោយគោរពទៅលើលក្ខខណ្ឌស្រប់ច្បាប់មួយចំនួនដូចខាងក្រោមនេះ៖

- បទល្មើសត្រូវចាត់ទុកថាត្រឹមត្រូវដោយការចាំបាច់ដើម្បីការពារខ្លួន ការពារអ្នកដទៃ ឬការពារទ្រព្យសម្បត្តិប្រឈមមុខនឹងការឈ្លានពានមួយដែលមិនត្រឹមត្រូវ។
- បទល្មើស និងការឈ្លានពានត្រូវតែកើតឡើងក្នុងពេលជាមួយគ្នា។
- គ្មានវិសមាមាត្រ រវាងមធ្យោបាយការពារដែលប្រើប្រាស់ និងទម្ងន់នៃការឈ្លានពាន[17]។

ដោយយោងទៅតាមខ្លឹមសារខាងលើ **ការការពារស្របច្បាប់** មាននិយមន័យថា **ការតបតដើម្បី ការពារខ្លួន ការពារអ្នកដៃ ឬការពារទ្រព្យសម្បត្តិប្រឈមមុខនឹងការឈ្លានពានមិនត្រឹមត្រូវ ដែលការតបតនោះមិនត្រូវបានច្បាប់ចាត់ទុកជាបទល្មើស**[18]។ ដូច្នេះហើយដើម្បីអោយជនដែលប្រព្រឹត្តបទល្មើស ត្រូវតែបង្ហាញឲ្យឃើញអំពីលក្ខខណ្ឌនៃការការពារ ស្ថានភាពនៃការការពារ និងភស្តុតាងនៃការការពារ ដែលកំណត់ដោយក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីឲ្យរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌលើការការពារស្របច្បាប់។

### ១.២.១ លក្ខខណ្ឌនៃការការពារ

ការការពារស្របច្បាប់ គឺជាប្រតិកម្មមួយដែលច្បាប់បានអនុញ្ញាតឲ្យកើតមានឡើង ពីសំណាក់ជនរងគ្រោះ ចំពោះអំពើឈ្លានពានណាមួយ ដើម្បីធ្វើការតបតក្នុងគោលបំណងការពារអាយុជីវិតខ្លួនឯង អាយុជីវិតអ្នកដទៃ ឬ ទ្រព្យសម្បត្តិ ទោះបីជាអំពើនោះបានស្តែងចេញជារូបភាពបែបហឹង្សាក៏ដោយ ក៏ប៉ុន្តែត្រូវស្ថិតនៅក្រោមលក្ខខណ្ឌនៃក្រមព្រហ្មទណ្ឌបានកំណត់តែប៉ុណ្ណោះ ពីព្រោះបើគ្មានការកំណត់ជាក់លាក់ទេ នោះការការពារស្របច្បាប់នេះនឹងបណ្តាលឲ្យមានការប៉ះ

[16] សារណាបញ្ចប់ការសិក្សារបស់ លោក ហុង សម្បត្តិ និងអ្នកស្រី និល ហ្វីលីប (ឆ្នាំ២០០២)។
[17] មាត្រា ៣៣. ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា. នស/រកម/១១០៩/០២២. ៣០ វិច្ឆិកា ២០០៩
[18] ទីស្តីការគណៈរដ្ឋមន្ត្រី, សន្ទានុក្រមច្បាប់ខ្មែរ អង់គ្លេស បារាំង ផ្នែកព្រហ្មទណ្ឌឆ្នាំ ២០១១,១

ពាល់យ៉ាងធ្ងន់ធ្ងរ។ តាមរយៈក្រមព្រហ្មទណ្ឌលក្ខខណ្ឌនៃការការពារស្របច្បាប់ យើងនឹងធ្វើការបង្ហាញជូនដូចខាងក្រោម៖

**១.២.១.១ ការឈ្លានពានមួយដែលមិនត្រឹមត្រូវ**

ការឈ្លានពានដែលមានលក្ខណៈមិនត្រឹមត្រូវ ពុំត្រូវបានអនុញ្ញាតដោយច្បាប់ ឬ ដោយអាជ្ញាធរស្របច្បាប់ឡើយ។ ការឈ្លានពាននេះ គឺសំដៅដល់រាល់អំពើទាំងអស់ដែលប្រឆាំង ឬបំពានច្បាប់ព្រហ្មទណ្ឌដែលកំពុងស្ថិតនៅជាធរមាន អំពើឈ្លានពាននេះ ក៏ជាការឈ្លានពានមួយដែលត្រូវបានក្រមព្រហ្មទណ្ឌកំណត់ថាជាបទល្មើស **ឧទាហរណ៍ដូចជា៖** អំពើមនុស្សឃាត, អំពើបង្ករបួសស្នាម, អំពើរំលោភសេពសន្ថវៈ ជាដើម។ ហើយការឈ្លានពាននេះជាចាំបាច់ត្រូវតែកើតឡើង មុនពេលមានការការពារ មានន័យថា លុះត្រាតែមានការឈ្លានពានមួយកើតឡើងជាមុនសិនទើបធ្វើឲ្យមាន ការការពារកើតឡើង ។ ការការពារនោះកើតឡើងដោយចាំបាច់ ដើម្បីការពារខ្លួន (រូបរាងកាយរបស់អ្នកការពារផ្ទាល់) ការពារអ្នកដទៃ (តតិយជន) ឬក៏ការពារទៅលើទ្រព្យសម្បត្តិ (អាចជាទ្រព្យសម្បត្តិផ្ទាល់ខ្លួន ឬជាទ្រព្យសម្បត្តិអ្នកដទៃ ឬ ទ្រព្យសម្បត្តិសាធារណៈ) ។ ការការពារនេះអាចការពារទៅលើការបំពានដែលកើតចេញពីអនិតិជន ឬជនវិបល្លាសស្មារតីផងដែរ ។ **ឧទាហរណ៍: ១.** ក កាន់កាំបិតចុងស្រួចចាក់ទៅលើ ខ ។ ឃើញដូច្នេះ ខ ក៏បានរុញតុមួយនៅក្បែរនោះទៅរាំងដំណើររបស់ ក ធ្វើឲ្យក៏ជ្រុះកាំបិតពីដៃ ។ អំពើរបស់ ក ជាការឈ្លានពានដែលមិនត្រឹមត្រូវ រីឯអំពើរបស់ ខ វិញជាការការពារ ។ **២.** ជនសង្ស័យបានវាយទៅលើមន្ត្រីនគរបាលយុត្តិធម៌នៅពេលដែលមន្ត្រីនគរបាលយុត្តិធម៌ចុះមកចាប់ខ្លួន ។ ការតបតមួយនេះមិនអាចចាត់ទុកជាការការពារស្របច្បាប់បានឡើយ ពីព្រោះមន្ត្រីនគរបាលយុត្តិធម៌បំពេញបេសកម្មនោះ ក្នុងក្របខណ្ឌនៃច្បាប់ហើយជនសង្ស័យ ក៏មិនអាចអះអាងនូវអំពើរបស់ខ្លួនថាជាការការពារខ្លួនដើម្បីគេចផុតពីការចាប់ខ្លួនបានដែរ។

**១.២.១.២ បទល្មើស និងការឈ្លានពានត្រូវកើតឡើងក្នុងពេលតែមួយ**

ករណីដែលនាំឲ្យមានការការពារជាធម្មានុរូបនៅក្នុងចំណុចនេះ គឺចាំបាច់ទាល់តែការឈ្លានពាននោះកើតឡើងពិតប្រាកដ និងកំពុងស្តែងឡើងជាក់ស្តែងពីការបំពាន ។ មានន័យថា ការឈ្លានពាន ឬ គ្រោះថ្នាក់ចំពោះប្រយោជន៍ដែលច្បាប់បានការពារ ត្រូវតែស្ថិតនៅជា **សត្យានុម័ត** ពោលគឺពុំមែនស្ថិតនៅក្នុងគំនិត ក្នុងអារម្មណ៍ ឬ ជាការគិតស្មានថានឹងមានគេបំពាននោះឡើយ។ ហើយការតបទល់ការការពារអាចនឹងទទួលស្គាល់យ៉ាងស្របច្បាប់ ប្រសិនបើការប្រព្រឹត្តធ្វើឡើងត្រូវចំពេលវេលា ពោលគឺត្រូវបានប្រព្រឹត្តនៅក្នុងចន្លោះពេលដែលច្បាប់អនុញ្ញាតឲ្យការពារ។ គឺការការពារប្រើបាននៅពេលដែលការឈ្លានពានចាប់ផ្តើមរហូតដល់ពេលបញ្ចប់នៃការឈ្លានពាន

នោះ។

យើងខ្ញុំនឹងធ្វើការបញ្ជាក់បន្ថែមនៅចំណុចខាងក្រោមនេះអំពីការការពារជាធម្មានុរូបទៅលើការឈ្លានពានដែលមិនត្រឹមត្រូវនេះ៖

• ការតបតមិនអាចកើតឡើងក្រោយពេលការឈ្លានពានត្រូវបានបញ្ចប់ឡើយ ។ វាមិនត្រូវបានចាត់ទុកថាជាការការពារស្របច្បាប់នោះឡើយ ពីព្រោះតាមទ្រឹស្តីវានឹងក្លាយទៅជា ការសងសឹក ការការពារហួលពេលកំណត់ ។ **ឧទាហរណ៍:** ក កាន់កាំបិតបំរុងចាក់ទៅលើ ខ ប៉ុន្តែមិនទាន់បានចាក់ផង ខ បានរត់គេចផុតហើយរត់ទៅផ្ទះរបស់ខ្លួនវិញ ។ រយៈពេល៣ម៉ោងក្រោយមក ខ បានកាន់កាំបិតបំរុងចាក់ទៅលើ ក វិញដោយសំអាងថាជាការការពារស្របច្បាប់ឡើយ ដោយសារតែការការពារកើតឡើង ៣ម៉ោងក្រោយមានការឈ្លានពានហើយ ខ ក៏បានរត់គេចខ្លួនផុតដែរ។ ដូច្នេះវាទៅជាការសងសឹកទៅវិញ ឬជាការការពារហួសពេលកំណត់តាមទ្រឹស្តីខាងលើ។

• ការតបតមិនអាចធ្វើមុនពេលមានអំពើនៃការឈ្លានពានបានដែរ ព្រោះប្រសិនបើការឈ្លានពានពុំទាន់ឃើញជាក់ស្តែងនោះទេ ឬគ្រាន់តែអាចកើតមានឡើងក្នុងពេលខាងមុខប៉ុណ្ណោះហើយការឈ្លានពាននោះ ត្រូវបានកម្រិតត្រឹមត្រូវតែជាការគម្រាមគំហែងថានឹងឈ្លានពានដល់ទ្រព្យសម្បត្តិ ឬរូបរាងកាយ នោះមិនអាចចាត់ទុកជាការតបតជាលក្ខណៈតបតបានឡើយ ហើយក៏មិនអាចចាត់ទុកថាជាការការពារស្របច្បាប់បានដែរ ។ **ឧទាហរណ៍:** ខ ស្មានថា ក កាន់កាំបិតបំរុងនឹងចាក់មកលើខ្លួន ក៏ស្ទុះទៅវាយក៏មួយដៃបណ្តាលឲ្យដួលតែតាមការពិត ក កាន់កាំបិតបំរុងនឹងទៅចំការទេ ។ ខ មិនអាចអះអាងថា ទង្វើរបស់ខ្លួនជាការពារនោះទេ ព្រោះពុំទាន់ស្តែងចេញនូវការឈ្លានពាននៅឡើយទេគ្រាន់តែជាការស្មានរបស់ ខ តែប៉ុណ្ណោះ ។ ខ ទេដែលជាអ្នកប្រព្រឹត្តបទល្មើស (អំពើបំពារបំពានច្បាប់)។

ដូច្នេះការការពារស្របច្បាប់ចាំបាច់ត្រូវតែកើតឡើងស្របគ្នារវាងបទល្មើស និងការឈ្លានពានគឺមិនត្រូវដាច់ចេញពីគ្នាឡើយ មានន័យថាសកម្មភាពនៃការការពារត្រូវតែធ្វើឡើងនៅក្នុងពេលតែមួយនឹងការឈ្លានពាន។ បើនិយាយជារួមទៅ អំពើឈ្លានពានត្រូវបានបញ្ចប់ ឬគ្រោះថ្នាក់ត្រូវបានបញ្ចប់ នោះសិទ្ធិនៃការការពារស្របច្បាប់ក៏រលត់ទៅតាមនឹងដែរ រីឯការការពារខ្លួនយឺតយ៉ាវ ក៏អាចបង្កើតបានជាការការពារខ្លួនដែលទទួលស្គាល់ដោយច្បាប់បានដែរ។

**១.២.១.៣ តុល្យភាពនៃមធ្យោបាយការការពារទៅនឹងការឈ្លានពាន**

ការការពារដែលធ្វើឡើងដើម្បីឲ្យមានលក្ខណៈស្របទៅនឹងច្បាប់ គឺការការពារត្រូវមានតុល្យភាពជាមួយអំពើឈ្លានពានដោយពិនិត្យទៅលើចរិត និងទំហំគ្រោះថ្នាក់នៃអំពើឈ្លានពាន។ នៅក្នុងទិដ្ឋភាព និងស្ថានភាពជាក់ស្តែង ការតទល់ត្រូវតែមានភាពស្មើគ្នា ដើម្បីធ្វើការរារាំង ឬ មានភាពធូរល្មមក្នុងការរុញច្រានការឈ្លានពាន ទប់ស្កាត់បានការអន្តរាយ ឬ មិនបណ្តែតបណ្តោយឲ្យមានការឈ្លានពានធ្ងន់ធ្ងរ ឬ បង្កការអន្តរាយដល់ផលប្រយោជន៍ដែលច្បាប់បានការពារ។ បើគ្មាន

តុល្យភាពរវាងមធ្យោបាយការពារដែលត្រូវបានប្រើប្រាស់ និងទម្ងន់នៃការឈ្លានពានទេ គឺមិនមែនជាមូលហេតុត្រឹមត្រូវក្នុងការដែលជៀសផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌនោះទេ។

**ឧទាហរណ៍:** ក កាន់កាំបិតបំរុងទៅចាក់ ខ ក្នុងបំណងលួចយកប្រាក់ក្នុងហោប៉ៅ ខ ។ ឃើញដូច្នេះ ខ ក៏បានទាញយកឈើជ្រុងដែលនៅក្បែរនោះទៅវាយលើ ក រហូតបែកក្បាលបណ្តាលឲ្យស្លាប់ ។ ក្នុងករណីបែបនេះមិនអាចចាត់ទុកថាជាការការពារខ្លួនស្របច្បាប់នោះទេ ព្រោះថារវាងមធ្យោបាយនៃការការពារ និងទម្ងន់នៃការឈ្លានពានគ្មានភាពសមាមាត្រនឹងគ្នាឡើយ ថ្វីត្បិតតែ ក មានបំណងលួចយកប្រាក់ពី ខ ដោយប្រើអាវុធ (កាំបិត) ក៏ពិតមែន ប៉ុន្តែការតបតរបស់ ខ មានលក្ខណៈធ្ងន់ធ្ងរពេក ម្យ៉ាងវិញទៀត ខ មានគោលដៅការពារទ្រព្យសម្បត្តិរបស់ខ្លួនតែប៉ុណ្ណោះ មិនអាចឈានដល់ការប្រើប្រាស់ហិង្សាធ្ងន់ធ្ងររហូតដល់ស្លាប់បែបនេះឡើយ ។ តម្លៃនៃទ្រព្យសម្បត្តិមិនអាចប្រៀបផ្ទឹមនឹងអាយុជីវិតមនុស្សបានឡើយ ។ ដូច្នេះ ខ ត្រូវតែទទួលខុសត្រូវចំពោះព្យសនកម្មរបស់បទល្មើសដែលខ្លួនបានប្រព្រឹត្តដោយមិនអាចអះអាងថាជាការការពារស្របច្បាប់បានឡើយ។

ដែលនៅក្នុងនោះអំពើតទល់អាចបង្កឲ្យមានការអន្តរាយដល់មនុស្ស ដែលប្រព្រឹត្តអំពើឈ្លានពានក្រោមរូបភាពដូចជា៖

- ការរារាំងនូវសេរីភាពខ្លះ
- បង្កឲ្យមានរបួសស្នាម ប៉ះពាល់ដល់សុខភាពតាមកំរិតខុសគ្នា
- អន្តរាយដោយផ្ទាល់លើទ្រព្យសម្បត្តិ។

ការអន្តរាយដែលកើតមានចំពោះជនឈ្លានពាន គឺជាការប្រព្រឹត្តឡើងដោយមានការទើសទាល់ ប៉ុន្តែនៅក្នុងហេតុចាំបាច់ដើម្បីរុញច្រានការឈ្លានពាន បញ្ចៀសនូវការអន្តរាយ និងការពារបាននូវប្រយោជន៍ស្របច្បាប់ឲ្យរួចផុតពីការឈ្លានពានទាំងនោះ។

### ១.២.២ ស្ថានភាពនៃការការពារ

នៅក្នុងមាត្រា១០៤ នៃក្រមព្រហ្មទណ្ឌអន្តរកាលបានបញ្ញត្តិថា **អំពើសម្លាប់ កាប់ វាយ ដើម្បីនឹងដេញមនុស្សដែលបំពាន ឬ ធ្វើសន្និច្ឆេទកម្ម (ការកាប់ ការគាស់ទំលុះទំលាយ) របង ជញ្ជាំង ទ្វារ បង្អួចផ្ទះជាទីលំនៅ ឬ រោងនៅរួមនឹង ផ្ទះក្នុងវេលាយប់ក្តី ដើម្បីនឹងការពារខ្លួនឯង ឬ អ្នកដ៏ទៃទល់នឹងចោរលួច ចោរប្លន់ក្តី ដើម្បីនឹងដេញតាមចោរទាំងនោះ នៅពេលដែលវាមានគ្រឿងអាវុធ ឬ ដែលវា តដៃវិញក្តី អំពើទាំងអម្បាលនេះ ត្រូវរាប់បញ្ចូលជាកិច្ចការពារជាធម្មានរូប** ។ ដោយឡែកនៅក្នុងក្រមព្រហ្មទណ្ឌបច្ចុប្បន្ននេះវិញ គឺមិនបានបញ្ញត្តិដូចក្រមព្រហ្មទណ្ឌអន្តរកាលនោះទេ គឺគ្រាន់តែបញ្ញត្តិអំពីស្ថានភាពមួយចំនួនដែលអាចធ្វើការចាត់ទុកវាថាជាការការពារស្របច្បាប់។ ដែលស្ថានភាពនៃការការពារទាំងអស់នោះមានដូចជា៖ **ការការពារខ្លួន ការការពារអ្នកដទៃ និងការការពារទ្រព្យសម្បត្តិ**[19]។

[19] មាត្រា ៣៣. ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា. នស/រកម/១១០៩/០២២. ៣០ វិច្ឆិកា ២០០៩

**១.២.២.១ ការការពារខ្លួន**

**ការការពារស្របច្បាប់**[20] គឺជាសិទ្ធិដែលរដ្ឋក៏ដូចជាក្រមព្រហ្មទណ្ឌបានផ្តល់ឲ្យប្រជាពលរដ្ឋអាចធ្វើសកម្មភាពសំដៅដល់ ការពារផលប្រយោជន៍របស់រដ្ឋ ផលប្រយោជន៍របស់សង្គម ឬ ផល-ប្រយោជន៍របស់បុគ្គល។

បទបញ្ញត្តិស្តីពីការការពារខ្លួនស្របច្បាប់ក្នុងក្រមព្រហ្មទណ្ឌ មានអត្ថន័យសំខាន់បំផុតក្នុងការបំផុសឲ្យមហាជនទាំងអស់ចូលរួមសកម្មភាពទប់ស្កាត់ ទប់ស្កាត់នូវរាល់អំពើដែលបង្កឲ្យមានការអន្តរាយដល់សង្គម ។ **ឧទាហរណ៍:** ដើម្បីការពារទប់ទល់ពីការចាប់បង្ខំ និងចាប់សង្កត់មកលើរូបនាងក្នុងបំណងរំលោភសេពសន្ថវៈពីសំណាក់បុរសម្នាក់ នារីរងគ្រោះក៏ស្រវាយកបានដុំថ្មមួយដុំនៅក្បែរនោះវាយលើបុរសឈ្លានពាននោះឲ្យរងរបួសដើម្បីរត់គេចខ្លួន ។ អំពើរបស់នារីរងគ្រោះ គឺជាការការពារស្របច្បាប់ ដោយការប្រព្រឹត្តបទល្មើសនេះគ្រាន់តែជាការការពារខ្លួនពីការឈ្លានពានមកលើរូបរាងកាយរបស់ខ្លួនពីសំណាក់បុរសនោះតែប៉ុណ្ណោះ ដូច្នេះនារីនោះមិនទទួលខុសត្រូវព្រហ្មទណ្ឌឡើយ ។

**១.២.២.២ ការការពារអ្នកដទៃ**

ការការពារស្របច្បាប់ មានដែនអនុវត្តដល់ការការពារអ្នកដទៃផងដែរ ពោលក៏មិនត្រឹមតែអាចការពារខ្លួន(សិទ្ធិលើបូរណភាពរូបរាងកាយ) ប៉ុណ្ណោះ ទេគឺអាចការពារដល់អ្នកដទៃបានទៀត។ **ឧទាហរណ៍:** ក បានឃើញ ខ កំពុងវាយក្មេងម្នាក់ដែលអាយុប្រហែល ១០ឆ្នាំ ។ ពេលនោះក បានចូលទៅឃាត់កុំឲ្យ ខ វាយក្មេងម្នាក់នោះបន្តទៀត ប៉ុន្តែ ខ មិនព្រមឈប់ ។ ក ក៏បានរុញ ខ ឲ្យដួលបណ្តាយឲ្យរងរបួស ។ អំពើរបស់ ក គ្រាន់តែចង់ការពារក្មេងម្នាក់នោះពីការឈ្លានពានរបស់ ខ តែប៉ុណ្ណោះ ដូច្នេះ ក មិនទទួលខុសត្រូវឡើយ ព្រោះវាជាទង្វើការការពារអ្នកដទៃ ។

**១.២.២.៣ ការការពារទ្រព្យសម្បត្តិ**

ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា មិនបានបញ្ជាក់ថាការការពារទ្រព្យសម្បត្តិស្ថិតនៅក្រោមរូបភាពបែបណាខ្លះនោះទេ គ្រាន់បញ្ជាក់ និងទាមទារឲ្យមានភាពសមាមាត្ររវាងប្រើប្រាស់ និងទម្ងន់នៃអំពើឈ្លានពានតែប៉ុណ្ណោះ ។ យើងសង្កេតឃើញថាទំហំ និងតម្លៃទ្រព្យសម្បត្តិមិនអាចយកមកប្រៀបធៀបនឹងអាយុជីវិតរបស់មនុស្សបានឡើយ ។ ការការពារទ្រព្យសម្បត្តិខ្លះអាចធ្វើឲ្យប៉ះពាល់ធ្ងន់ធ្ងរដល់បូរណភាពរូបរាងកាយ ពេលខ្លះអាចឈានដល់អាយុជីវិតទៀតផង។ អាយុជីវិតរបស់មនុស្សមិនអាចយកអ្វីមកវាស់បានឡើយ ហើយក៏មានតម្លៃជាប្រាក់កាស។ ប្រសិនបើការការពារទ្រព្យសម្បត្តិមានលក្ខណៈធ្ងន់ធ្ងរ រហូតដល់ធ្វើឲ្យប៉ះពាល់ដល់អាយុជីវិត នោះក៏ក្រមព្រហ្មទណ្ឌមិនអនុញ្ញាតឲ្យមានស្ថានភាពការការពារបែបនេះកើតឡើងដែរ ពោលគឺ ការ

[20] សាស្ត្រាចារ្យជូន ប៊ុនធី នីតិព្រហ្មទណ្ឌទូទៅ

ការពារមាន ព្រំដែនសមស្របនឹងការឈ្លានពានតែប៉ុណ្ណោះ មិនអាចឈានដល់ការប៉ះពាល់ដល់អាយុជីវិតឡើយ ។ **ឧទាហរណ៍:** ក បានឃើញ ខ មានបំណងចង់លួចយកម៉ូតូរបស់ខ្លួន ។ ដើម្បីទប់ទល់នឹងការឈ្លានពានរបស់ ខ ក បានយកដំបងទៅវាយដៃ និងខ្លួនរបស់ចោរ រហូតដល់រងរបួសយ៉ាងធ្ងន់ធ្ងរ។ ករណីនេះវាគ្មានភាពសមាមាត្រមធ្យោបាយប្រើប្រាស់ និងទម្ងន់នៃអំពើឈ្លានពាន ម្យ៉ាងវិញទៀតទង្វើរបស់ ក អាចបណ្តាលឲ្យ ខ ស្លាប់បាន ទោះជាម៉ូតូមានតម្លៃប៉ុណ្ណា ក៏គ្មានតម្លៃស្មើនឹងអាយុជីវិតមនុស្សដែរ ទោះបីជា ខ អ្នកប្រព្រឹត្តអំពើជាបទល្មើស (អំពើឈ្លានពាន) ក៏ដោយ ប៉ុន្តែជីវិតរបស់ ខ មានតម្លៃមិនអាចប្រើប្រាស់ការការពារបែបនេះមកការពារបានឡើយ ពោលគឺមិនមែនជាការការពារស្របច្បាប់នោះទេ ។ ដូច្នេះ ក ត្រូវតែទទួលខុសត្រូវព្រហ្មទណ្ឌនូវបទល្មើសដែលខ្លួនបានប្រព្រឹត្ត។

ការការពារត្រូវតែចាំបាច់សំរាប់ ការការពារខ្លួន ការពារអ្នកដទៃ ការពារទ្រព្យសម្បត្តិ ពោលគឺដើម្បីស្រោចស្រង់ផលប្រយោជន៍ដែលកំពុងទទួល ការគំរាមគំហែង ហើយការតបតរបស់អ្នកការពារជាមធ្យោបាយតែមួយគត់ដែលក្រមព្រហ្មទណ្ឌ បានអនុញ្ញាតក្នុងគោលបំណងបញ្ចៀសការឈ្លានពាន មានន័យថានៅតែគ្រោះថ្នាក់មកដល់ជនរងគ្រោះគ្មានវិធី និងមធ្យោបាយផ្សេងក្នុងការដោះស្រាយដោយមានវិធី ឬ មធ្យោបាយតែមួយគត់ គឺការប្រព្រឹត្តបទល្មើសដើម្បីតបតទៅនឹងការឈ្លានពានដែលកំពុងនៅចំពោះមុខ ដោយក្នុងកាលៈទេសៈមិនអាចរត់គេចខ្លួនបាន ឬ ការប្ដឹងទៅសមត្ថកិច្ចជាដើម។

### ១.២.៣ សច្ចធារណ៍នៃការការពារស្របច្បាប់

តាមរយៈក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៩ ក្របខណ្ឌនៃការការពារស្របច្បាប់បានកំណត់ចេញជាលក្ខខណ្ឌមួយករណីទៀត ដែលពាក់ព័ន្ធនឹងការបង្ហាញភស្តុតាង ពោលគឺជនជាប់ចោទមិនចាំបាច់លើកសំអាង ពីការការពារស្របច្បាប់របស់ខ្លួនតាមលក្ខខណ្ឌនៃមាត្រា ៣៣ នៃក្រមព្រហ្មទណ្ឌឡើយ។

សន្មតថាជាការការពារស្របច្បាប់ នៅក្នុងករណីដូចតទៅ៖

១. បទល្មើសត្រូវបានប្រព្រឹត្ត ដើម្បីរុញច្រានការចូលក្នុងពេលយប់ ដោយការកាប់គាស់ទម្លុះទម្លាយ ដោយហិង្សា ឬដោយកលល្បិចនៅក្នុងកន្លែងដែលមានមនុស្សនៅ ។

២. បទល្មើសបានប្រព្រឹត្តដើម្បីការពារខ្លួនប្រឆាំងនឹងការលួច ឬ ការប្លន់ដែលអនុវត្តដោយហិង្សា ។ សច្ចធារណ៍[21] នៃការការពារស្របច្បាប់ ពុំមានលក្ខណៈដាច់ខាតទេ ។ ហើយម្យ៉ាងវិញ

[21] ទីស្តីការគណៈរដ្ឋមន្ត្រី, សន្ទានុក្រមច្បាប់ខ្មែរ អង់គ្លេស បារាំង ផ្នែកព្រហ្មទណ្ឌឆ្នាំ ២០១១,៦៤
សច្ចធារណ៍ មានន័យថា កាសន្មតទុកជាមុន

ទៀតគ្រប់សកម្មភាពដែលកើតមាន ដោយសច្ចធារណ៍បែបនេះគឺអាចរំលាយទៅវិញបានដោយភស្តុតាងផ្ទុយ[22]។

ចារីដែលបានប្រព្រឹត្តគ្រាន់តែបង្ហាញភស្តុតាង អំពីស្ថានភាពនៃការការពាររបស់ខ្លួនដូចមានចែងក្នុងមាត្រាខាងលើដោយមិនចាំបាច់បង្ហាញភស្តុតាងពី លក្ខខណ្ឌនៃការការពារស្របច្បាប់ ដូចមានចែងក្នុងមាត្រា ៣៣ ឡើយ ។ **ឧទាហរណ៍:** ក បានត្រលប់មកផ្ទះវិញនៅម៉ោង ១១ យប់ ។ គាត់បានឃើញស្រមោលខ្មៅមួយរត់ពួនក្រោមគ្រែ ហើយឃើញទ្វាមានស្នាមគាស់ទម្លុះទម្លាយ ព្រមទាំងសម្ភារៈក្នុងផ្ទះមានសភាពរាយប៉ាយ ។ ឃើញដូច្នេះ ក ក៏បានទាញពូថៅកាប់ទៅលើជននោះបណ្តាលឲ្យរងរបួស។ ករណីនេះ ក គ្រាន់តែបង្ហាញភស្តុតាងពីការគាស់ទម្លុះទម្លាយផ្ទះខ្លួនដែលជាភស្តុតាងជាក់ស្តែងដែលមិនចាំបាច់បង្ហាញពីលក្ខខណ្ឌដូចមានចែងក្នុងមាត្រា ៣៣ ឡើយពោលគឺក្រមព្រហ្មទណ្ឌសន្មតថា ក បានប្រព្រឹត្តបទល្មើសក្នុងលក្ខខណ្ឌនៃការការពារស្របច្បាប់។

ប៉ុន្តែសច្ចធារណ៍នៃការការពារស្របច្បាប់ ពុំមានលក្ខណៈដាច់ខាតឡើយ ។ ក្នុងករណីដែលតំណាងអយ្យការ អាចរកភស្តុតាងផ្ទុយបាននោះមិនអាចចាត់ទុកថាជាការការពារស្របច្បាប់ឡើយ ហើយសច្ចធារណ៍នៃការការពារស្របច្បាប់នោះ នឹងត្រូវបានរំលាយ។

## ១.៣ ស្ថានភាពចាំបាច់

ស្ថានភាពចាំបាច់ ជាករណីដែលមនុស្សម្នាក់ចង់គេចផុតពីគ្រោះអាសន្នជាក់ស្តែងមួយដែលកំពុងគម្រាមកំហែងផលប្រយោជន៍របស់រដ្ឋ ផលប្រយោជន៍ស្របច្បាប់របស់ខ្លួន ឬរបស់អ្នកដទៃក្នុងកាលៈទេសៈដែលពុំមានវិធីណាផ្សេង ក្រៅពីការធ្វើសកម្មភាពដែលបង្កឲ្យមានការអន្តរាយមួយមានទំហំតូចជាងការអន្តរាយដែលត្រូវបានទប់ស្កាត់ ។ ការបង្កឲ្យមានការអន្តរាយ ក្នុងស្ថានភាពនេះពុំមែនជាបទល្មើសឡើយ ។ នៅចំពោះមុខស្ថានភាពមួយដែលទាមទារឲ្យមនុស្ស ត្រូវជំនះឲ្យបាននូវគ្រោះអាសន្ន ដែលកំពុងគម្រាមកំហែងដល់បណ្តាលផលប្រយោជន៍ស្របច្បាប់ ហើយមានវិធីតែមួយគត់គឺការបង្កឲ្យមានការអន្តរាយដល់ផលប្រយោជន៍ផ្សេងទៀតដែលក្រមព្រហ្មទណ្ឌបានការពារ ហើយទំហំនៃការអន្តរាយត្រូវតែតូចជាងការអន្តរាយដែលគេបានទប់ស្កាត់[23]។ ជារួម ស្ថានភាពចាំបាច់ គឺស្ថានភាពពិសេស ដែលមិនអាចខកខានបានដោយជៀសមិនផុតពីការប្រព្រឹត្តអ្វីមួយ[24]។ **បុគ្គលដែលស្ថិតនៅក្នុងការចាំបាច់ត្រូវតែប្រព្រឹត្ត មិនទទួលខុសត្រូវព្រហ្មទណ្ឌទេ ។ ស្ថានភាពចាំបាច់ត្រូវមានលក្ខខណ្ឌដូចខាងក្រោម៖**

[22] មាត្រា ៣៥. ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា. នស/រកម/១១០៩/០២២. ៣០ វិច្ឆិកា ២០០៩

[23] ជួន ប៊ុនធី, នីតិព្រហ្មទណ្ឌទូទៅ

[24] ទីស្តីការគណៈរដ្ឋមន្ត្រី, សន្ទានុក្រមច្បាប់ខ្មែរ អង់គ្លេស បារាំង ផ្នែកព្រហ្មទណ្ឌឆ្នាំ ២០១១,៦៧

- **បទល្មើសត្រូវបានចាត់ទុកថាត្រឹមត្រូវដោយការចាំបាច់ដើម្បីការពារខ្លួន ការពារអ្នកដទៃ ឬ ការពារទ្រព្យសម្បត្តិ ប្រឆាំងនឹងគ្រោះថ្នាក់ដែលកំពុងកើតមាន ឬដែលនឹងកើតមាន និង**
- **គ្មានវិសមាមាត្ររវាងមធ្យោបាយ និងទម្ងន់នៃគ្រោះថ្នាក់[25]។**

ដើម្បីឲ្យស្ថានភាពចាំបាច់ក្លាយជាមូលហេតុដែលរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌ ចារីដែលបានប្រព្រឹត្តបទល្មើស ចាំបាច់ត្រូវតែបង្ហាញភស្តុតាងពីការកើតឡើងនៃគ្រោះថ្នាក់ ដែលកំពុងកើត ឬ រៀបនឹងកើត ការចាំបាច់នៃការការពារព្រមទាំង ភាពសមាមាត្ររវាងមធ្យោបាយការពារ និងទម្ងន់នៃគ្រោះថ្នាក់។

### ១.៣.១ គ្រោះថ្នាក់ដែលកំពុងកើត ឬរៀបនឹងកើត

ជាដំបូង ចារីដែលប្រព្រឹត្តបទល្មើសស្ថានភាពចាំបាច់ ត្រូវរកឲ្យឃើញនូវភស្តុតាងដែលនៅជុំវិញឲ្យខ្លួនប្រព្រឹត្តបទល្មើស ដែលគ្រោះថ្នាក់នោះអាចជាគ្រោះថ្នាក់ដែលគម្រាមកំហែងដល់ចារីផ្ទាល់ ឬក៏តតិយជន ហើយក៏អាចជាកាតគម្រាមគំហែងលើទ្រព្យសម្បត្តិដែលជារបស់ខ្លួនក្តី ឬ មិនមែនក្តី ។

#### ១.៣.១.១ គ្រោះថ្នាក់ដែលកំពុងកើតឡើង

គ្រោះថ្នាក់ដែលកំពុងកើតឡើង ជាគ្រោះថ្នាក់ដែលកើតឡើងយ៉ាងពិតប្រាកដ មិនមែនជាការស្រមើលស្រមៃរបស់ចារីឡើយ ពោលគឺជាការប្រព្រឹត្តបទល្មើសក្នុងស្ថានភាពចាំបាច់ត្រូវតែជាការបញ្ចៀស គ្រោះថ្នាក់ដែលកំពុងកើតមានឡើងយ៉ាងពិតប្រាកដ ហើយក៏មិនមែនគ្រោះថ្នាក់ជាយថាហេតុដែរ ។ **ឧទាហរណ៍:** ដើម្បីបញ្ចៀសគ្រោះថ្នាក់ដែលកំពុងកើតឡើង ព្រោះតែគ្រោះអគ្គីភ័យ ក បានវាយបំបែកកញ្ចក់បង្អួចអ្នកជិតខាងដែលនៅក្បែរនោះក្នុងគោលបំណងចូលទៅជួយជនរងគ្រោះដែលកំពុងជាប់នៅក្នុងនោះ ។ ករណីនេះ ការវាយបំបែកបង្អួចផ្ទះរបសើអ្នកជិតខាងវាជាបទល្មើស ប៉ុន្តែការធ្វើទង្វើបែបនេះវាជាស្ថានភាពចាំបាច់ដែល ក ចាំបាច់ត្រូវតែធ្វើបែបនេះ ដើម្បីជួយសង្គ្រោះជនរងគ្រោះដែលជាប់នៅខាងក្នុងអគ្គីភ័យ ពីព្រោះអាយុជីវិតរបស់មនុស្សមានតម្លៃជាងកញ្ចក់បង្អួចនោះ ហើយក៏គ្មានវិធីណាដែលអាចជួយជនរងគ្រោះបានក្រៅពីវិធីនេះដែរ ហើយបើនិយាយពីព្យសនកម្មវិញវាមានលក្ខណៈតិចតួចបំផុត ។

#### ១.៣.១.២ គ្រោះថ្នាក់ដែលរៀបនឹងកើត

ចំនុចនេះមានលក្ខណៈខុសប្លែកពីចំនុចខាងលើបន្តិច ដោយគ្រោះថ្នាក់នោះរៀបនឹងកើតឡើងនៅពេលខាងមុខយ៉ាងពិតប្រាកដ គឺចារីប្រព្រឹត្តបទល្មើសនោះ ដោយឃើញថាគ្រោះថ្នាក់អាចបង្កព្យសនកម្មយ៉ាងធ្ងន់ធ្ងរដល់សង្គម ហើយការប្រព្រឹត្តបទល្មើសក្នុងស្ថានភាពចាំបាច់ បញ្ចៀសគ្រោះថ្នាក់ដែលកំពុងតែរៀបនឹងកើតមានឡើងនៅខាងមុខយ៉ាងពិតប្រាកដ ។ **ឧទាហរណ៍:** គ្រោះ

[25] មាត្រា ៣៥. ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា. នស/រកម/១១០៩/០២២. ៣០ វិច្ឆិកា ២០០៩

អគ្គីភ័យកំពុងឆាបឆេះផ្ទះប្រជាពលរដ្ឋ ដែលកំពុងរស់នៅក្បែរសារមន្ទីរជាតិ ។ ដើម្បីបញ្ចៀសគ្រោះថ្នាក់ដែលកំពុងកើតមានឡើងប្រជាពលរដ្ឋនៅម្តុំនោះបានវាយកម្ទេចផ្ទះប្រជាពលរដ្ឋ ដែលនៅជិតបំផុតប្រមាណជាអស់ ៣ខ្នង ដើម្បីការពារការឆេះរាលដាលដល់សារមន្ទីរជាតិនោះ ។ ក្នុងករណីនេះប្រជាពលរដ្ឋដែលបានវាយកម្ទេចផ្ទះប្រជាពលរដ្ឋ ដែលនៅជិតបំផុតដើម្បីការពារការឆាបឆេះដល់សារមន្ទីរជាតិ។ សារមន្ទីរជាតិជាផលប្រយោជន៍ធំមួយរបស់រដ្ឋដែលចាំបាច់ការពារ ពោលគឺបើបាត់បង់សារមន្ទីរជាតិនេះទៅ សង្គមត្រូវប្រឈមមុខនឹងផលប៉ះពាល់ធ្ងន់ធ្ងរ ជារួមគឺបាត់បង់នូវសម្បត្តិបេតិកភណ្ឌជាតិ ហើយផលប៉ះពាល់នេះក៏មានទំហំធំជាងការខូចខាតផ្ទះរបស់ប្រជាពលរដ្ឋដែលនៅក្បែរនោះ ។ ម៉្យាងវិញទៀតប្រជាពលរដ្ឋដែលជួយសង្គ្រោះបានប្រើប្រាស់គ្រប់មធ្យោបាយហើយ តែគ្មានមធ្យោបាយណាក្រៅពីកម្ទេចផ្ទះនោះ មិនតែប៉ុណ្ណោះត្រូវតែមានភាពច្បាស់លាស់ថាអគ្គីភ័យនេះពិតជាអាចរាលដាលដល់សារមន្ទីរជាតិយ៉ាងប្រាកដមែន ទង្វើបែបនេះត្រូវចាត់ទុកជាស្ថានភាពចាំបាច់ ។

### ១.៣.២ ការការពារខ្លាំងចាំបាច់

សកម្មភាពដែលត្រូវបានបំពេញដើម្បីបង្ការគ្រោះថ្នាក់ ក៏ត្រូវតែមានលក្ខណៈចាំបាច់ជាទីបំផុតមានន័យថា ការប្រព្រឹត្តបទល្មើសគឺជាជម្រើសចុងក្រោយ និងប្រសើរបំផុត ព្រមទាំងជាជម្រើសតែមួយគត់ដើម្បីបញ្ចៀសគ្រោះថ្នាក់ដែលកំពុងកើតឡើង និងរៀបនឹងកើតឡើងនៅចំពោះមុខ ហើយការការពារគ្រោះថ្នាក់នោះមានលក្ខណៈជា ការចាំបាច់ ឬអត់ គឺអាស្រ័យទៅតាមអង្គហេតុនីមួយៗ ។ **ឧទាហរណ៍:** ១. ដើម្បីគេចពីការដួលរលំដើមឈើដែលបណ្តាលមកពីរន្ទះមកលើរថយន្តខ្លួនអ្នកបើកបរបានបើករថយន្តឡើងទៅលើជញ្ជើមថ្នល់ បណ្តាលឲ្យខូចខាតដល់អីវ៉ាន់ដែលកំពុងដាក់លក់នៅតាមដងផ្លូវ ។ ក្រមព្រហ្មទណ្ឌមិនបានចាត់ទុកទង្វើនេះថាជាបទល្មើសព្រហ្មទណ្ឌឡើយ ហើយស្ថិតនៅក្នុងស្ថានភាពនេះអ្នកបើកបរគ្រាន់តែការពារទ្រព្យសម្បត្តិរបស់ខ្លួនតែប៉ុណ្ណោះ បើមិនដូច្នេះទេគ្រោះថ្នាក់នឹងកើតមានឡើង បណ្តាលមកពីដើមឈើបាក់រលំលើដែលវានឹងបង្កការខូចខាតទ្រព្យសម្បត្តិ (រថយន្ត) និង អាចបង្កគ្រោះថ្នាក់ដល់អាយុជីវិតម្ចាស់រថយន្តថែមទៀតផង។ ២. ដើម្បីគេចពិការដួលរលំដើមឈើមកឡើរថយន្តរបស់ខ្លួនដែលម្ចាស់រថយន្តតែងតែយករថយន្តនៅទីនោះជារៀងរាល់ថ្ងៃ ម្ចាស់រថយន្តនោះបានសម្រេចចិត្តកាប់ដើមឈើនោះចោលដែលដើមឈើនោះគឺជារបស់អ្នកជិតខាងខ្លួន។ នេះគឺជាគ្រោះថ្នាក់ដែលកើតឡើងតាមគំនិត និងការស្រមើស្រមៃរបស់ចារីតែប៉ុណ្ណោះ វាមិនទាន់មានការកើតឡើងជាក់ស្តែងឡើយ ។ ដូច្នេះវាមិនមែនជាការបញ្ចៀសគ្រោះថ្នាក់ដែលកំពុងកើតឡើង ឬគ្រោះថ្នាក់ដែលរៀបនឹងកើតឡើង នោះទេ ។

### ១.៣.៣ ភាពសមាមាត្ររវាងមធ្យោបាយការពារ និងទម្ងន់នៃគ្រោះថ្នាក់

បទល្មើសដែលចារីបានប្រព្រឹត្តចាំបាច់ត្រូវតែ រកភស្តុតាងបង្ហាញឲ្យឃើញពីភាពសមាមាត្រគ្នា រវាងមធ្យោបាយការពារ និងទម្ងន់នៃគ្រោះថ្នាក់ចំពោះស្ថានភាពចាំបាច់ ។ ភាពសមាមាត្រគ្នារវាងមធ្យោបាយ និងទម្ងន់នៃគ្រោះថ្នាក់ត្រូវតែវាយតម្លៃទៅតាមអង្គហេតុហេតុនីមួយៗ ថាតើក្នុងកាលៈទេសៈដែលមានការឈ្លានពានកើតឡើង ចារីជ្រើសរើសយកបល្មើសដែលមានតម្លៃ និងទំហំតូចជាងគ្រោះថ្នាក់ ឬក៏ជ្រើសយកបទល្មើសដែលមានតម្លៃ និងទំហំប្រហាក់ប្រហែលនឹងគ្រោះថ្នាក់ដែលកំពុងកើតឡើង ឬដែលកំពុងតែរៀបនឹងកើតឡើង ។ ការប្រើប្រាស់មធ្យោបាយនៃការការពារមិនអាស្រ័យទៅលើការនឹកឃើញរបស់ខ្លួននៅចំពោះមុខ ហើយក្នុងស្ថានភាពខ្លះទៀត ចារីជ្រើសយកការបង្កការខូចខាតដែលមានទំហំប្រហាក់ប្រហែលនឹង គ្រោះថ្នាក់ដែលកើតមានឡើងម៉្យាងទៀតចារីត្រូវពិចារណាឲ្យបានច្បាស់លាស់មុននឹងជ្រើសរើសយកវិធីណាមួយ សម្រាប់យកមកធ្វើការការពារ ពីព្រោះការឈ្លានពាននីមួយៗ មានលក្ខណៈខុសៗគ្នា បើនិយាយឲ្យចំទៅគឺត្រូវតែពិនិត្យដល់ការឈ្លានពាននោះជាការឈ្លានពានទ្រព្យសម្បត្តិ ឬ ការឈ្លានពានបានដល់អាយុជីវិត បើការការពារមានលក្ខណៈសមាមាត្ររវាងទម្ងន់នៃគ្រោះថ្នាក់ និងមធ្យោបាយនៃការការពារ ។ ប្រសិន បើការប្រើប្រាស់មធ្យោបាយនៃការពារមានលក្ខណៈលើសលប់ជាងគ្រោះថ្នាក់នោះ យើងក៏មិនអាចចាត់ទុកអំពើនោះជាអំពើស្របច្បាប់បានដែរ ។ មិនត្រឹមតែប៉ុណ្ណោះការការពារមិនតម្រូវចាំបាច់តែត្រូវប្រព្រឹត្តអំពើដែលជាបទល្មើសទើបអាចបញ្ចៀសការឈ្លានពានបាននោះទេ គេអាចរត់រកអាជ្ញាធរឲ្យមកជួយធ្វើអន្តរាគមន៍ក៏បាន ប្រសិនបើការឈ្លានពាននោះមានលក្ខណធ្ងន់ធ្ងរដែលខ្លួនមិនអាចទប់ទល់បាន ។

# ជំពូកទី២

# ភាពមិនអាចទម្លាក់កំហុសបាន

**ភាពមិនអាចទម្លាក់កំហុសបាន** ជាមូលហេតុមួយទៀតដែលស្ថិតនៅក្រោមមូលហេតុដែលរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌបន្ទាប់ពីមូលហេតុយុត្តិកម្មនៃបទល្មើស ។ **ភាពមិនអាចទម្លាក់កំហុសបាន** ជាមូលហេតុដែលទាញចេញពីស្ថានភាពផ្ទាល់របស់ចារី ហើយការមិនអាចទម្លាក់កំហុសបានទៅលើចារីនេះផងដែរ សង្កត់ធ្ងន់ទៅលើចារីផ្ទាល់ ដែលគ្មានលក្ខណៈគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវនូវទង្វើដែលខ្លួនបានប្រព្រឹត្ត ពីព្រោះចារីមានបញ្ញាស្មារតីមិនប្រក្រតី ឬពុំមានសេរីភាពគ្រប់គ្រាន់ក្នុងការគ្រប់គ្រងនូវអំពើល្មើសដែលកំពុងកើតឡើង។ ខាងក្រោមនេះជាបណ្តាលមូលហេតុទាងឡាយដែលស្ថិតនៅក្រោម **ការមិនអាចទម្លាក់កំហុសបាន** ដែលមានចែងក្នុងក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ដែលរួមមាន វិបល្លាសស្មារតី(២.១) អនុភាពនៃកម្លាំង ឬ ការបង្ខំ(២.២) និងករណីពិសេសចំពោះអនីតិជន(២.៣)។

## ២.១ វិបល្លាសស្មារតី

មូលហេតុនៃភាពមិនទម្លាក់កំហុសបានទី១ គឺវិបល្លាសស្មារតី ។ ក្រមព្រហ្មទណ្ឌបានបញ្ញត្តិនូវចំនុចវិបល្លាសស្មារតីមានលក្ខណៈពិសេសដូចខាងក្រោម៖

- កាលបើជនណាម្នាក់ប្រព្រឹត្តបទល្មើស នៅពេលដែលជននោះកើតវិបល្លាសស្មារតីដែលធ្វើឲ្យបាត់បង់នូវការដឹងខុសត្រូវរបស់ខ្លួន ជននោះមិនទទួលខុសត្រូវព្រហ្មទណ្ឌ ។
- កាលបើជនណាម្នាក់បានប្រព្រឹត្តបទល្មើស នៅដែលជននោះកើតវិបល្លាសស្មារតីដែលបន្ថយនូវការដឹងខុសដឹងត្រូវរបស់ខ្លួន ជននោះនៅតែទទួលខុសត្រូវព្រហ្មទណ្ឌ។ ប៉ុន្តែតុលាការត្រូវគិតគូអំពីបញ្ហានេះកាលណាតុលាការកំណត់ទោស ។
- កាលបើជនណាម្នាក់ប្រព្រឹត្តបទល្មើស នៅពេលដែលជននោះកើតវិបល្លាសស្មារតី ដោយសារការប្រើប្រាស់គ្រឿងស្រវឹង គ្រឿងញៀន ឬសារជាតិដែលច្បាប់ហាមឃាត់ មិនអាចរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌ[26]។

យោងតាមមាត្រាខាងលើបង្ហាញឲ្យចេញជាករណីសំខាន់ៗដូចខាងក្រោម៖

### ២.១.១ និយមន័យ

ជាដំបូងយើងចាំបាច់ត្រូវដឹងពីនិយមន័យនៃពាក្យ **វិបល្លាសស្មារតី** ជាមុនសិន ។ វិបល្លាស-ស្មារតី ត្រូវបានគេដឹងជាទូទៅថា ជាការប្រែប្រួល ដែលនាំឲ្យបាត់បង់ ឬ ថយចុះនូវការដឹងខុសត្រូវ[27]។ វិបល្លាសស្មារតី គឺសំដៅទៅលើមនុស្សដែលបាត់បង់ការគ្រប់គ្រងទៅលើទង្វើដែលខ្លួន

[26] មាត្រា ៣១. ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា. នស/រកម/១១០៩/០២២. ៣០ វិច្ឆិកា ២០០៩

[27] ទីស្តីការគណៈរដ្ឋមន្ត្រី, សន្ទានុក្រមច្បាប់ខ្មែរ អង់គ្លេស បារាំង ផ្នែកព្រហ្មទណ្ឌឆ្នាំ ២០១១,៦៤

ប្រព្រឹត្ត។ វិបល្លាសស្មារតីអាចមានប្រភពមកពីគ្រោះថ្នាក់ ឬ មកពីជម្ងឺណាមួយជាដើម។ ដោយសារតែប្រព័ន្ធសសៃប្រសាទ មានសកម្មភាពមិនប្រក្រតីបណ្តាលឲ្យចារីបាត់បង់នូវលទ្ធភាពនៅក្នុងការយល់ដឹងពីពិភពខាងក្រៅជុំវិញខ្លួន ហើយពុំអាចត្រួតពិនិត្យសកម្មភាពរបស់ខ្លួនបានទេ[28]។

**២.១.២ លក្ខខណ្ឌដែលចាត់ទុកជាជនវិបល្លាសស្មារតី**

លក្ខខណ្ឌដែលចាត់ទុកជាជនវិបល្លាសស្មារតីត្រូវបានកំណត់យ៉ាងច្បាស់ ពីព្រោះថាមានតែជនដែលបំផ្លាញចោលការយល់ដឹងទាំងស្រុងរបស់ចារី ពោលគឺសមត្ថភាពក្នុងការដឹងនៃអំពើរបស់ខ្លួនកំពុងប្រព្រឹត្ត ឬ ក៏គ្មានការដឹងខុសត្រូវក្នុងការប្រព្រឹត្តអំពើ និងជនដែលបានបំផ្លាញចោលទាំងស្រុងនូវសមត្ថភាពក្នុងការត្រួតពិនិត្យនូវសកម្មភាពដែលខ្លួនកំពុងតែប្រព្រឹត្ត ។

**២.១.៣ ករណីពិសេស**

ករណីពិសេសនៃវិបល្លាសស្មារតីបានចែកចេញជា ២ ករណី ធំៗគឺ វិបល្លាសស្មារតីពាក់កណ្តាល ឬការបន្ថយការយល់ដឹង និងវិបល្លាសស្មារតីដោយការប្រើប្រាស់ថ្នាំ[29]។

**២.១.៣.១ វិបល្លាសស្មារតីពាក់កណ្តាល ឬ បន្ថយការយល់ដឹង**

វិបល្លាសស្មារតីពាក់កណ្តាល ឬបន្ថយការយល់ដឹង សំដៅដល់ចារីនៅពេលដែលប្រព្រឹត្តបទល្មើស គឺប្រព្រឹត្តដោយសារតែការបាត់បង់ការយល់ដឹងមួយផ្នែក ឬអាចបន្ថយការយល់ដឹងនៃអំពើដែលខ្លួនកំពុងប្រព្រឹត្តតែប៉ុណ្ណោះ។ ចំពោះករណីនេះក្រមព្រហ្មទណ្ឌក៏បានបញ្ញត្តិយ៉ាងច្បាស់លាស់ថា កាលណាបើជនណាម្នាក់ប្រព្រឹត្តបទល្មើសនៅពេលដែលជននោះកើតវិបល្លាសស្មារតីដែលបន្ថយនូវការដឹងខុសត្រូវរបស់ខ្លួន ជននោះនៅតែទទួលខុសត្រូវព្រហ្មទណ្ឌ[30]។ ដូច្នេះបើទោះបីជាចារីមានបញ្ហាស្មារតីពាក់កណ្តាល ឬវិបល្លាសស្មារតីនោះគ្រាន់តែធ្វើឲ្យចារីបន្ថយការយល់ដឹងរបស់ខ្លួនក៏មិនអាចជាមូលហេតុដែលរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌដែរ។ ប៉ុន្តែក្រមព្រហ្មទណ្ឌមិនមានលក្ខណៈដាច់ខាតចំពោះជនដែលមានបញ្ហាវិបល្លាសស្មារតីពាក់កណ្តាល ឬ បន្ថយការយល់ដឹងឡើយ ពោលគឺ ក្រមព្រហ្មទណ្ឌបានកំណត់ឲ្យតុលាការគិតគូរពីមូលហេតុនៃវិបល្លាសស្មារតីដែលនាំឲ្យបន្ថយការយល់ដឹងនៅពេលដែលជនបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ចំពោះការកំណត់ទោសទៅលើជននោះ។

**២.១.៣.២ ការប្រើប្រាស់ថ្នាំ**

គ្រឿងញៀន គ្រឿងស្រវឹង និងថ្នាំមួយចំនួនអាចធ្វើឲ្យមនុស្សបាត់បង់ស្មារតី បាត់បង់ការគ្រប់គ្រង ចំពោះទង្វើដែលខ្លួនបានប្រព្រឹត្ត ពីព្រោះការប្រើប្រាស់ថ្នាំអាចធ្វើឲ្យខូចខាតដល់ប្រព័ន្ធ

---

[28] វុណា ពណ្ណារិទ្ធ កែសម្រួលដោយ ចាំ ស៊ីណាត, នីតិព្រហ្មទណ្ឌទូទៅ

[29] មាត្រា ៣១. ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា. នស/រកម/១១០៩/០២២. ៣០ វិច្ឆិកា ២០០៩

[30] មាត្រា ៣១. ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា. នស/រកម/១១០៩/០២២. ៣០ វិច្ឆិកា ២០០៩

សរសៃប្រសាទ ។ វិបល្លាសស្មារតីដែលកើតចេញពីការប្រើប្រាស់គ្រឿងញៀន គ្រឿងស្រវឹង និងថ្នាំដែលច្បាប់ហាមឃាត់ច្រើនតែកើតចេញពីឆន្ទៈផ្ទាល់របស់ចារីតែម្តង ហើយក៏មិនអាចចាត់ទុកថាជាមូលហេតុដែលនាំឲ្យមានការផុតពីការទទួលខុសត្រូវដែរ ។ **ឧទាហរណ៍:** បុរសម្នាក់បានប្រើប្រាស់ថ្នាំញៀន ឬ ផឹកគ្រឿងស្រវឹង បណ្តាលឲ្យបាត់បង់ការគ្រប់គ្រងលើខ្លួនឯង ហើយក៏បានទៅវាយបុរសម្នាក់ទៀតដែលនៅក្បែរនោះបណ្តាលឲ្យរងរបួសធ្ងន់ ។ ជនល្មើសនោះមិនអាចប្រើប្រាស់ ឬលើកយកនូវមូលហេតុដែលខ្លួនស្រវឹង យកមកធ្វើជាហេតុផលមួយដែលអាចឲ្យខ្លួនមានការរួចផុតពីកាទទួលខុសត្រូវព្រហ្មទណ្ឌនោះទេ ។ ដោយឡែកបុរសដែលប្រព្រឹត្តនោះនឹងត្រូវតែប្រឈមមុខនូវរាល់កំហុសទាំងអស់ដែលខ្លួនបានប្រព្រឹត្ត ពីព្រោះថាមូលហេតុដែលខ្លួនប្រុងនឹងលើកយកមកអះអាងនៅទីនេះមិនមានច្បាប់ណាមួយបញ្ជាក់ថាអាចយកមកធ្វើជាភស្តុតាងផ្ទុយបាននោះទេ ។

### ២.១.៤ ការបង្ហាញភស្តុតាង

ការបង្ហាញភស្តុតាងជាមធ្យោបាយតែមួយគត់ ដើម្បីធ្វើឲ្យវិបល្លាសស្មារតីជាមូលហេតុដែលធ្វើអោយមានការរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌ។ គេត្រូវរកឲ្យឃើញភស្តុតាង ថាជននោះពិតជាមានវិបល្លាសស្មារតីពិតប្រាកដមែនក្នុងពេលដែលជននោះប្រព្រឹត្តបទល្មើស ។ រីឯវិបល្លាសស្មារតីដែលកើតមុន ឬក្រោយពេលប្រពឹត្តបទល្មើសវាពុំមែនជាមូលហេតុដែលនាំអោយមានការរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌឡើយ ។ ដើម្បីអោយវិបល្លាសស្មារតីក្លាយជាមូលហេតុដែលនាំឲ្យចារីរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌនោះ គឺចាំបាច់ត្រូវស្វែងរកអោយឃើញភស្តុតាងដើម្បីយកមកធ្វើការបញ្ជាក់ពីអត្ថិភាព[31] នៃវិបល្លាសស្មារតីក្នុងពេលដែលចារីប្រព្រឹត្តបទល្មើស ពោលគឺគ្មាននរណាម្នាក់អាចមកអះអាងពីជនណាម្នាក់ថាមានវិបល្លាសស្មារតី នៅក្នុងពេលដែលជននោះប្រព្រឹត្តបទល្មើសនោះឡើយ គឺមានតែវេជ្ជបណ្ឌិតជំនាញតែប៉ុណ្ណោះ ដែលអាចធ្វើការបញ្ជាក់បានអំពី ភស្តុតាងនៃវិបល្លាសស្មារតីនេះ ប៉ុន្តែនេះគ្រាន់តែជាយោបល់វិនិច្ឆ័យលើជននេះតែប៉ុណ្ណោះ ចំណែកការជឿរបាន ឬមិនបាន គឺអាស្រ័យទៅលើការសម្រេចរបស់តុលាការចំពោះកាលដែលត្រូវទទួលខុសត្រូវ ឬក៏អត់ ។

វិបល្លាសស្មារតី គឺជាមូលហេតុដែលរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌដែលតម្រូវឲ្យបង្ហាញពីអត្ថិភាពនៃវិបល្លាសស្មារតី នៅក្នុងកំឡុងពេលដែលចារីបានប្រព្រឹត្តនូវអំពើល្មើស ហើយអាចត្រូវបញ្ជាក់ពីបណ្តា ភស្តុតាងទាំងឡាយនោះតាមរយៈវេជ្ជបណ្ឌិតជំនាញ ពីព្រោះមានតែវេជ្ជបណ្ឌិតជំនាញប៉ុណ្ណោះទើប មានសិទ្ធិបង្ហាញភស្តុតាងទាំងនោះ ។ មិនតែប៉ុណ្ណោះ ក្នុងក្រមព្រហ្មទណ្ឌមិនអនុញ្ញាតិឲ្យរួចផុតពីការទទួលខុសត្រូវឡើយ ចំពោះជនណាដែលវិបល្លាសស្មារតី ដោយ

[31] ទីស្តីការគណៈរដ្ឋមន្ត្រី, សន្ទានុក្រមច្បាប់ខ្មែរ អង់គ្លេស បារាំង ផ្នែកព្រហ្មទណ្ឌឆ្នាំ ២០១១,៦៩
អត្ថិភាព មានន័យថា គឺជាការកើតមុន

សារការប្រើប្រាស់ថ្នាំ និង ដោយសារតែការបន្ថយការយល់ដឹង ឬ វិបល្លាសស្មារតីពាក់កណ្តាលឡើយ ពោលគឺគ្រាន់តែកំណត់ឲ្យតុលាការ ពិចារណាចំពោះការកំណត់អំពីទោសតែប៉ុណ្ណោះ ។

## ២.២.អានុភាពនៃកម្លាំង ឬ ការបង្ខំ

មូលហេតុនៃភាពមិនអាចទំលាក់កំហុសបានទី២ គឺ **អានុភាពនៃកម្លាំង ឬ ការបង្ខំ** ។ បុគ្គលដែលប្រព្រឹត្តបទល្មើសក្រោមអានុភាពនៃកម្លាំង ឬ ការបង្ខំ ដែលបុគ្គលនេះមិនអាចទប់ទល់បាន គឺបុគ្គលនេះមិនត្រូវបានទទួលខុសត្រូវព្រហ្មទណ្ឌឡើយ ។ កម្លាំង និងការបង្ខំនេះ អាចបណ្តាលចេញមកពីព្រឹត្តិការណ៍ក្រៅឆន្ទៈ របស់មនុស្សតែប៉ុណ្ណោះ ។ កម្លាំង និង ការបង្ខំនេះ ត្រូវតែមិនអាចមើលឃើញជាមុន និង មិនអាចជៀសវាងបាន[32]។

យើងខ្ញុំនឹងធ្វើការបង្ហាញជូននូវរាលចំណុចសំខាន់ដែលមានការពាក់ព័ន្ធនឹង កម្លាំង ឬ ការបង្ខំ នៅខាងក្រោម។

### ២.២.១.និយមន័យ

នៅក្នុងក្រមព្រហ្មទណ្ឌមិនបានកំណត់ ឬ បង្ហាញពីនិយមន័យ នៃពាក្យថា **អានុភាពនៃកម្លាំង ឬ ការបង្ខំ** នេះនោះទេ រីឯក្រមព្រហ្មទណ្ឌចាស់ឆ្នាំ១៩៦៧ បានឲ្យនិយមន័យនៃពាក្យនេះថាកាលបើមានភស្តុតាងថាមានកម្លាំងអ្វីមួយបានបង្ខំឲ្យជនណាម្នាក់ប្រព្រឹត្តបទល្មើសអ្វីមួយ កាលមិនអាចទប់ទល់ទៅលើកម្លាំងនោះបាន ក៏ប្រព្រឹត្តបទល្មើសនោះទៅ ។ ជនដែលប្រព្រឹត្តបទល្មើសនេះ មិនត្រូវបានអោយទទួលខុសត្រូវចំពោះអំពើដែលខ្លួនបានប្រព្រឹត្តនោះឡើយ[33]។ កម្លាំងដែលមកបង្ខំនោះ គឺគ្រោះថ្នាក់ដែលបណ្តាលឲ្យមានអាសន្នយ៉ាងធំបំផុត ។ ពាក្យថា អាសន្នយ៉ាងធំបំផុត គឺមានន័យថា គ្រោះថ្នាក់គ្រោះថ្នាក់ដែលធ្លាក់មកលើនរណាម្នាក់ ក្នុងពេលជាបន្ទាន់ក្រៃពេកមិនអាចចៀសវាងបានដោយងាយ ហើយអ្នកមានគ្រោះថ្នាក់នឹងដោះខ្លួនឲ្យរួចពីគ្រោះនោះបាន ដោយលុះត្រាតែខ្លួនបានប្រព្រឹត្តបទល្មើសណាមួយ ទើបខ្លួនរួចផុតពីគ្រោះនោះ ម្យ៉ាងទៀត គ្រោះថ្នាក់នោះកាលកើតមកក៏មិនមែនកើតពីឆន្ទៈផ្ទាល់របស់ចារីនៃបទល្មើសនោះដែរ និងមិនមែនខ្លួនចារីនោះជាអ្នកបង្កបង្កើតបណ្តាលឲ្យមានគ្រោះថ្នាក់[34]។

មាត្រា៩៩ នៃក្រមព្រហ្មទណ្ឌចាស់ ជានិយមន័យដ៏សំខាន់ក្នុងការឈានទៅដល់ការស្វែងយល់ពីនិយមន័យពីមាត្រា៣៦ នៃក្រមព្រហ្មទណ្ឌ និង មាត្រា៩៦ នៃក្រមព្រហ្មទណ្ឌចាស់នៃព្រះរាជាណាចក្រកម្ពុជា ពីព្រោះមាត្រាទាំងពីរនេះមានខ្លឹមសារប្រហាក់ប្រហែលគ្នា។ ដូច្នេះតាមរយៈខ្លឹមសារនៃមាត្រា៩៧ នៃក្រមព្រហ្មទណ្ឌចាស់(១៩៦៧) យើងអាចសន្និដ្ឋានបាននូវនិយមន័យនៃពាក្យ

[32] មាត្រា ៣៦. ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា. នស/រកម/១១០៩/០២២. ៣០ វិច្ឆិកា ២០០៩

[33] មាត្រា៩៦,ក្រមព្រហ្មទណ្ឌចាស់ឆ្នាំ១៩៦៧

[34] មាត្រា៩៧,ក្រមព្រហ្មទណ្ឌចាស់ឆ្នាំ១៩៦៧

ថា **អានុភាពនៃកម្លាំង និង ការបង្ខំ** គឺសំដៅដល់គ្រោះថ្នាក់យ៉ាងធំបំផុតនឹងត្រូវធ្លាក់មកលើជនណាម្នាក់ក្នុងពេលជាបន្ទាន់ដោយមិនអាចនឹងជៀសវាងបាន លុះត្រាតែចារីបានប្រព្រឹត្តបទល្មើស ហើយបទល្មើសនោះទៀតសោតក៏មិនបានចេញពីឆន្ទៈផ្ទាល់របស់ចារីដែរ ។

**២.២.២.ប្រភេទនៃកម្លាំង ឬ ការបង្ខំ**

ប្រភេទនៃកម្លាំង ឬ ការបង្ខំអាចស្តែងចេញជា ២ករណី គឺការបង្ខំលើរូបរាងកាយ និងការបង្ខំលើផ្លូវចិត្តៈ

**២.២.២.១.ការបង្ខំលើរូបរាងកាយ**

ការបង្ខំលើរូបរាងកាយ គឺសំដៅទៅដល់ការបង្ខំលើរូបរាងកាយរបស់ចារី ដែលវាគឺជាហេតុមួយដែលបណ្តាលអោយចារីប្រព្រឹត្តនូវអំពើដែលជាបទល្មើសដោយហាមឃាត់ខ្លួនឯងមិនបាន។ កម្លាំងនៃការបង្ខំនេះស្តែងចេញពីរ ករណីៈ

**ទី១** ការបង្ខំដែលជាកម្លាំងបង្ខំពីខាងក្រៅ ដូចជា គ្រោះធម្មជាតិ សត្វ ឬ ក៏មកពីតតិយជន។ ឧទាហរណ៍: អ្នកបើករថយន្តបានរេចង្កូតទៅបុកអ្នកលក់ដូរនៅតាមចិញ្ចើមផ្លូវដោយសារតែកម្លាំងខ្យល់ព្យុះ ហើយបានធ្វើឲ្យអ្នកលក់នោះបានស្លាប់បាត់បង់ជីវិត និងមានរបួសជាច្រើននាក់ ។ គ្រោះថ្នាក់នេះគឺបណ្តាលមកពីខ្យល់ព្យុះទើបបណ្តាលឲ្យអ្នកបើករថយន្តរេចង្កូត ពោលគឺអ្នកបើកបរនោះមិនអាចគ្រប់គ្រងបាននូវហេតុការដែលកំពុងតែកើតមាននេះបានឡើយ ទើបបង្កើតបានជាបទល្មើសនេះឡើងមក ។

**ទី២** ការបង្ខំដែលជាកម្លាំងបង្ខំមកពីស្ថានភាពខាងក្នុងរបស់ចារី សំដៅទៅដល់ស្ថានភាពខាងក្នុងរបស់ចារី ដែលមិនអាចឲ្យចារីគ្រប់គ្រងខ្លួនឯងបាន ។ ឧទាហរណ៍: អ្នកបើករថយន្តបានរេចង្កូតទៅបុកអ្នកលក់ដូរនៅតាមចិញ្ចើមផ្លូវដោយសារតែស្ថានភាពសុខភាពខុសប្រក្រតី ដែលបណ្តាលមកពីជើងរបស់អ្នកបើកស្រាប់តែរមួលក្រពើរភ្លាមៗ ហើយក៏បានជាបង្កឲ្យមានគ្រោះថ្នាក់នេះឡើង។ ក្នុងស្ថានភាពនេះគេមិនអាចចាត់ទុកថា ជំងឺរបស់ចារីគឺជាជំងឺដែលកើតចេញពីឆន្ទៈរបស់ចារីឡើយ ទោះបីជាវាកើតចេញពីស្ថានភាពខាងក្នុងរបស់ចារីក៏ដោយ។

**២.២.២.២.ការបង្ខំលើផ្លូវចិត្ត**

ការបង្ខំលើផ្លូវចិត្ត សំដៅដល់ការបង្ខំលើឆន្ទៈរបស់ចារី ពោលគឺជា កម្លាំងគាបសង្កត់មកពីប្រភពខាងក្រៅ ដែលបណ្តាលឲ្យចារីប្រព្រឹត្តអំពើជាបទល្មើសដោយមិនអាចជៀសវាងបាន។ ដូច្នេះចារីអាចរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌបាន ដែលបណ្តាលមកពីការបង្ខំលើផ្លូវចិត្តរបស់ចារី។ ក្នុងក្រមព្រហ្មទណ្ឌ កម្លាំងនៃការបង្ខំអាចកើតឡើងក្រៅឆន្ទៈរបស់ចារីតែប៉ុណ្ណោះ ចំណែកឯការបង្ខំដែលកើតមកពីចារីផ្ទាល់មិនត្រូវបានចាត់ទុកថាជាការរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌឡើយ ។

- **ប្រភពមកពីព្រឹត្តិការណ៍ក្រៅឆន្ទៈរបស់ចារី** នេះជាមូលហេតុតែមួយគត់ដែលក្រមព្រហ្មទណ្ឌទទួលថាវា ជាមូលហេតុដែលនាំឲ្យមានការរួចផុតពីការទទួលខុសត្រូវ ព្រហ្មទណ្ឌ ។ ដើម្បីឲ្យកម្លាំងគាបសង្កត់ និងការគំរាមកំហែងក្លាយជាមូលហេតុដែលនាំឲ្យចារីរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌ ចារីត្រូវចាបាច់បង្ហាញពីភស្តុតាងថាការគំរាមកំហែងនោះគឺពិតជាផ្ទុយនឹងច្បាប់ពិតប្រាកដមែន ដែលនាំឲ្យចារីមិនមានវិធីផ្សេងណាមួយក្រៅពីប្រព្រឹត្តបទល្មើសឡើយ ។ **ឧទាហរណ៍:** ចោរប្រដាប់អាវុធមួយក្រុមបានធ្វើសកម្មភាពលួចហាងពេជ្រមួយកន្លែង ។ ពួកចោរបានយកកាំភ្លើងភ្ជង់បុគ្គលិកក្នុងហាងនោះ ឲ្យប្រគល់គ្រាប់ពេជ្រ ដែលកំពុងតែលក់ទៅឲ្យពួកវា ។ ក្នុង កាលៈទេសៈនោះ បុគ្គលិកនៅក្នុងហាងទាំងអស់សុទ្ធតែទទួលបាននូវការគាបសង្កត់ និងការគំរាមកំហែងពីក្រុមចោរ ដូច្នេះសកម្មភាពក្នុងការប្រគល់គ្រាប់ពេជ្ររបស់បុគ្គលិកទាំងអស់នោះមិនត្រូវបានចាត់ទុកថាជាបទល្មើស ឬក៏ជាអំពើល្មើសអ្វីនោះឡើយ ហើយបុគ្គលិទាំងអស់នោះមិនត្រូវបានទទួលខុសត្រូវរាល់ការខាតបង់នោះទេ ។
- **ប្រភពមកពីចារីផ្ទាល់** ប្រភពដែលកើតចេញពីឆន្ទៈរបស់ចារីផ្ទាល់ គឺមិនអាចក្លាយជាមូលហេតុដែលនាំឲ្យមានការរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌនោះឡើយ ព្រោះថា ក្នុងក្រមព្រហ្មទណ្ឌបានបញ្ញាត្តិថា មានតែបទល្មើសដែលកើតក្រៅឆន្ទៈរបស់ចារីតែប៉ុណ្ណោះទើបចាត់ទុកថាជាមូលហេតុដែលរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌ ។ **ឧទាហរណ៍:** ដោយសារតែការជេរប្រមាថមើលងាយលើខ្លួន ទើបចារីបង្ខំចិត្តប្រព្រឹត្តបទល្មើស ដើម្បីបញ្ឈប់ការជេរប្រមាថនោះ ។ ក្នុងករណីនេះមិនអាចចាត់ទុកថាជាការ បង្ខំចិត្តលើចារីក្នុងការប្រព្រឹត្តបទល្មើសនោះឡើយ ព្រោះថាព្រឹត្តិការណ៍នេះ គឺជាការកើតចេញពីចារីផ្ទាល់តែម្តង ។

### ២.២.៣.លក្ខណៈនៃកម្លាំង និងការបង្ខំ

លក្ខណៈនៃកម្លាំង និងការបង្ខំត្រូវបានកំណត់ចេញជា ពីរករណី គឺ**កម្លាំង និងការបង្ខំដែលមិនអាចមើលឃើញជាមុនបាន** និង **កម្លាំង និងការបង្ខំដែលមិនអាចជៀសវាងបាន**[35]។

#### ២.២.៣.១.កម្លាំង និងការបង្ខំដែលមិនអាចមើលឃើញជាមុនបាន

កម្លាំង និងការបង្ខំដែលមិនអាចមើលឃើញជាមុនបាន ពោលគឺ នៅពេលដែលចារីប្រព្រឹត្តបទល្មើស គឺបានន័យថាជនដែលប្រព្រឹត្តបទល្មើសនោះមិនបានដឹងជាមុនឡើយថាអំពើដែលតតិយជនបង្ខំឲ្យធ្វើនោះជាបទល្មើស ហើយអំពើនោះក៏ពុំមែនកើតចេញពីឆន្ទៈរបស់ខ្លួននោះដែរ។

[35] មាត្រា ៣៦. ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា. នស/រកម/១១០៩/០២២. ៣០ វិច្ឆិកា ២០០៩

**ឧទាហរណ៍:** នៅពេលដែលអ្នកបើកបរ បើកបរទៅបុកនរណាម្នាក់ ដោយសារតែកង់ឡានរបស់ខ្លួនមានភាពសឹករិចរិល និងបានប្រើប្រាស់ជាយូរមកហើយនោះ អ្នកបើកបរនោះពុំអាចយកមូលហេតុថាខ្លួនមិនបានដឹងពីមុនអំពីកង់ឡានដែលខ្លួនកំពុងតែបើក ដែលបណ្តាលឲ្យមានគ្រោះថ្នាក់ដោយសារតែការបើកចុះទួលរអិល ឬក៏បែកកង់ហើយរេចង្កូតទៅបុកមនុស្សឲ្យរងរបួស ។ មូលហេតុដែលអ្នកបើកបរបានលើកមកនេះ គឺមិនអាចក្លាយទៅជាមូលហេតុដែលនាំឲ្យមានការរួចផុតពីការទទួលខុសត្រូវនោះឡើយ ពីព្រោះថាការមើលថែរក្សាយានយន្តវាជាកាតព្វកិច្ចរបស់អ្នកដែលជាម្ចាស់ ឬ អ្នកបើកបរគ្រប់រូបដែលចាំបាច់ត្រូវតែត្រួតពិនិត្យយានយន្តរបស់ខ្លួនមុនពេលធ្វើចរាចរនៅលើដងផ្លូវសាធារណៈ ។ ដែលទាំងអស់នេះវាជាកំហុសរបស់អ្នកបើកបរទាំងស្រុង ដែលមិនមានការប្រុងប្រយ័ត្ន ហើយអ្នកបើកបរក៏មិនអាចសំអាងហេតុផលថាជាកម្លាំង និងការបង្ខំដែលមិនអាចមើលឃើញជាមុនបានឡើយ។ រាល់ការខ្វះការប្រុងប្រយ័ត្ន និងការធ្វេសប្រហែសរបស់ជនណាម្នាក់គឺវាមិនមែនជាកម្លាំង និងការបង្ខំដែលមិនអាចមើលឃើញជាមុនបាន ដូច្នេះជននោះក៏មិនអាចលើកហេតុផលនោះយកមកធ្វើ ជាមូលហេតុដែលការរួចផុតពីការទទួលខុសត្រូវនោះបានឡើយ ។

**២.២.៣.២.កម្លាំង និងការបង្ខំដែលមិនអាចជៀសវាងបាន**

កម្លាំង និងការបង្ខំដែលមិនអាចជៀសវាងបាន គឺជាកម្លាំង និងការបង្ខំដែលលុបបំបាត់ទាំងស្រុងនូវសេរីភាពក្នុងការប្រព្រឹត្តអំពើរបស់ចារី ពោលគឺ ចារីត្រូវតែស្ថិតនៅក្នុងស្ថានភាពមួយដែលមិនអាចជៀសវាងបាន ឬ អលទ្ធភាពដាច់ខាតក្នុងការទប់ទល់ទៅនឹងកម្លាំង និងការបង្ខំខាងលើ មិនតែប៉ុណ្ណោះចារីគឺគ្មានវិធីផ្សេងណាមួយក្រៅពីប្រព្រឹត្តបទល្មើសនោះទេ។ រីឯរាល់ការបញ្ជាក់នូវភស្តុតាងដែលធ្វើឲ្យមានការរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌវិញ គឺតម្រូវឲ្យចារីបង្ហាញថាខ្លួនប្រព្រឹត្តបទល្មើសនេះក៏ព្រោះតែមានការបង្ខំដែលខ្លួនមិនអាចជៀសវាងបាន និងមិនមានវិធីផ្សេងក្រៅតែពីប្រព្រឹត្តបទល្មើស ។ ប៉ុន្តែរាល់ការបង្ហាញនូវភស្តុតាងបែបនេះគឺមានការពិបាកមែនទែន ក្នុងការដែលអាចធ្វើឲ្យមានការជឿរជាក់ពីតុលាការ ដូចនេះប្រសិនបើពុំអាចបញ្ជាក់បាននោះទេគឺចាំបាច់ជនដែលប្រព្រឹត្តនោះត្រូវមានការទទួលខុសត្រូវព្រហ្មទណ្ឌ ។ **ឧទាហរណ៍:** ជនគ្រប់រូបមិនអាចសំអាងថាការបង្ខំ និងការគំរាមកំហែងថានឹងសម្លាប់របស់ចោរប្រសិនណាបើខ្លួនមិនយកម៉ូតូដែលចោរនោះបានលួចមកទៅលក់ទេចោរនោះនឹងសម្លាប់រូបខ្លួនចោល មកធ្វើជាមូលហេតុនៃការរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌបានឡើយ ព្រោះថានៅក្នុងរយះពេលនោះខ្លួនអាចទៅប្រាប់ ឬ ប្តឹងអាជ្ញាធរមានសមត្ថកិច្ចបាននៅពេលចោរត្រលប់មកវិញ ហើយម្យ៉ាងទៀតម៉ូតូនោះក៏មិនអាចលក់បានភ្លាមៗនោះដែរ ដូច្នេះជននោះមានលទ្ធភាពគ្រប់គ្រាន់នៅក្នុងការទប់ស្កាត់បាន ហើយនេះក៏មិនមែនជាកម្លាំង និងការបង្ខំដែលមិនអាចជៀសវាងបាននោះទេ ហើយជននោះមិន

អាចយកមកធ្វើជាសំអាងអំពីភស្តុតាងថានេះជាកម្លាំង និងការបង្ខំដែលមិនអាចជៀសវាងបាននោះដែរ ។

## ២.៣.ករណីពិសេសចំពោះអនីតិជន

អនីតិជន ជាជនដែលច្បាប់មិនទាន់ឲ្យទទួលខុសត្រូវលើអំពើដែលខ្លួនបានប្រព្រឹត្ត និងជាជនដែលច្បាប់កំណត់ឲ្យទទួលខុសត្រូវលើអំពើរបស់ខ្លួនដោយមានកម្រិត[36]។ រីឯក្រមព្រហ្មទណ្ឌមាត្រា ៣៨ មិនបានឲ្យនិយមន័យនៃពាក្យថា អនីតិជន នេះឡើយប៉ុន្តែបានកំណត់ថា **នីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌត្រូវបានកំណត់អាយុចាប់ពី ១៨ឆ្នាំឡើងទៅ** ។ តាមរយៈមាត្រានេះ អនីតិជនមានន័យថាជាជនដែលមានអាយុតិចជាង ១៨ឆ្នាំ ហើយក៏ជាជនដែលមិនទទួលខុសត្រូវព្រហ្មទណ្ឌផងដែរ ។ ប៉ុន្តែ តុលាការអាចប្រកាសពីទណ្ឌកម្មទៅលើអនីតិជន ដែលមានអាយុចាប់ពី ១៤ឆ្នាំឡើងទៅប្រសិនបើកាលៈទេសៈនៃទោស ឬបុគ្គលិកលក្ខណៈរបស់ជននោះតម្រូវ[37]។

តាមរយៈនិយមន័យ និងមាត្រានេះគឺបានបង្ហាញឲ្យចេញជាពីរករណី គឺ អនីតិជនដែលមានអាយុក្រោម ១៨ឆ្នាំ និងអនីតិជនដែលមានអាយុក្រោម ១៤ឆ្នាំ ហើយតើអនីតិជនទាំងពីរប្រភេទនេះនឹងមានការទទួលខុសត្រូវ និងមិនទទួលខុសត្រូវព្រហ្មទណ្ឌយ៉ាងដូចម្ដេចខ្លះ យើងនឹងធ្វើការបង្ហាញដូចខាងក្រោម៖

### ២.៣.១.អនីតិជនអាយុក្រោម ១៨ឆ្នាំ

អនីតិជន គឺជាជនទាំងឡាយណាដែលច្បាប់បានកំណត់ថាជាជនដែលរួចផុតពីការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ[38] ប៉ុន្តែនៅតែមានការទទួលខុសត្រូវខ្លះដែលច្បាប់បានបញ្ញាត្តិឲ្យអនីតិជនដែលមានអាយុចាប់ពី១៤ឆ្នាំ ដល់ ក្រោម១៨ឆ្នាំ គឺ តុលាការអាចធ្វើការប្រកាសពីទណ្ឌកម្មព្រហ្មទណ្ឌនេះបាន ។ ទណ្ឌកម្មនេះសំដៅដល់ការដាក់ទោសលើអនីតិជន ហើយការដាក់ទោសនេះទៀតសោតមានលក្ខណៈខុសពីនីតិជនដូចមានចែងក្នុងក្រមព្រហ្មទណ្ឌ និងក្រមនីតិវិធីព្រហ្មទណ្ឌជាដើម ។

រាល់ការដាក់ទោស និងការអនុវត្តទោសលើអនីតិជន គឺត្រូវមានការពិនិត្យទៅលើបុគ្គលិកលក្ខណៈរបស់អនីតិជន និងកាលៈទេសៈនៃបទល្មើសរបស់អនីតិជនតម្រូវ មានន័យថាតុលាការត្រូវតែវិនិច្ឆ័យទៅតាមអង្គហេតុនីមួយៗ ដូចជា អនីតិជនដែលមានអាយុចាប់ពី ១៤ឆ្នាំ ដល់ ១៨ឆ្នាំ បានប្រព្រឹត្តបទល្មើស ដូចជា បទរំលោភសេពសន្ថវៈ ជាដើម តុលាការអាចយកកាលៈទេសៈនៃការប្រព្រឹត្តបទល្មើសនេះ យកមកធ្វើជាមូលហេតុដែលអាចប្រកាសប្រកាសបានពីទណ្ឌកម្មលើអនីតិ

[36] ទីស្ដីការគណៈរដ្ឋមន្ត្រី, សន្ធានុក្រមច្បាប់ខ្មែរ អង់គ្លេស បារាំង ផ្នែកព្រហ្មទណ្ឌឆ្នាំ ២០១១,៦៩

[37] មាត្រា ៣៩. ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា. នស/រកម/១១០៩/០២២. ៣០ វិច្ឆិកា ២០០៩

[38] មាត្រា ៣៨. ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា. នស/រកម/១១០៩/០២២. ៣០ វិច្ឆិកា ២០០៩

ជននោះបាន ។ នៅក្នុងក្រមព្រហ្មទណ្ឌ បានបញ្ញត្តិយ៉ាងជាក់លាក់ចំពោះទោសដែលត្រូវអនុវត្ត ទៅលើអនីតិជនកាលណាតុលាការសម្រេចផ្តន្ទាទោសទៅលើអនីតិជនដែលមានអាយុចាប់ពី ១៤ ឆ្នាំ ឡើងទៅ គឺមូលទោសលើការចោទប្រកាន់ត្រូវបានបន្ថយក្នុងលក្ខខណ្ឌដូចតទៅ៖

១.អតិបរមានៃទោសដាក់ពន្ធនាគារត្រូវបន្ថយពាក់កណ្តាល។

២.ប្រសិនបើអតិបរមានៃទោសនោះ គឺជាទោសដាក់ពន្ធនាគារអស់មួយជីវិត អតិបរមាត្រូវបន្ថយមកដាក់ពន្ធនាគារ២០ឆ្នាំ ។

៣.អប្បរមានៃទោសដាក់ពន្ធនាគារ ត្រូវបន្ថយពាក់កណ្តាល ប្រសិនបើអប្បរមានេះលើសពី ១ថ្ងៃ ។

៤.អប្បរមា និងអតិបរមានៃទោសពិន័យជាប្រាក់ត្រូវបន្ថយពាក់កណ្តាល[39]។

ដូច្នេះ ការកំណត់ទោសដែលយកមកអនុវត្តលើអនីតិជន ត្រូវបន្ថយកណ្តាលដូចមានចែងក្នុងមាត្រាខាងលើ ។ **ឧទាហរណ៍:** បទរំលោភសេពសន្ថវៈ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ឆ្នាំ ដល់ ១០ ឆ្នាំ[40]។ បើយោងតាមគោលការណ៍ខាងលើ គឺតុលាការត្រូវតែគិតដល់អប្បរមានៃទោស ។ បទល្មើសរំលោភសេពសន្ថវៈនេះ ប្រសិនបើតុលាការកាត់ទោសឲ្យជនល្មើសជាប់ពន្ធនាគារ ៨ឆ្នាំ ប៉ុន្តែនៅពេលប្រកាសសាលក្រម គឺជនត្រូវចោទដែលជាអនីតិជននោះ ត្រូវបន្ថយទោសមកត្រឹម ៤ឆ្នាំ វិញ ។ ក្នុងករណីនេះ បើទោះបីជាមូលទោសត្រូវបានបន្ថយក៏ដោយ (បន្ថយអតិបរមានៃទោសដាក់ពន្ធនាគារមកត្រឹមកម្រិតចិរវេលាមួយស្មើ ឬ តិចជាង ៥ឆ្នាំ) ក៏បទល្មើសដែលចោទប្រកាន់នៅតែជាបទល្មើសឧក្រិដ្ឋដដែល[41]។

នីតិវិធីនៃការឃាត់ខ្លួនរបស់អនីតិជនមានលក្ខណៈពិសេស មិនដូចជាការឃាត់ខ្លួននីតិជនឡើយពោលគឺ ពុំមានការពន្យាពេលនៃការឃាត់ខ្លួនឡើយបើបុគ្គលដែលឃាត់ខ្លួននោះជាអនីតិជន[42]។ ចំណែកឯ ការឃុំខ្លួនបណ្តោះអាសន្នវិញ ក៏មានការកំណត់ដោយឡែកខុសពីនីតិជនផងដែរ[43]។

អនីតិជនដែលមានអាយុចាប់ពី ១៤ឆ្នាំ ដល់ ក្រោម១៨ឆ្នាំ មិនអាចរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌ កាលបើជននោះបានប្រព្រឹត្តបទល្មើស ហើយការអនុវត្តទោសនេះទៀតសោតចាំបាច់ឲ្យតុលាការ ពិនិត្យមើលទៅលើបុគ្គលិកលក្ខណៈ និងកាលៈទេសៈនៃបទល្មើសរបស់អនីតិជន។

---

[39] មាត្រា ១៦០. ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា. នស/រកម/១១០៩/០២២. ៣០ វិច្ឆិកា ២០០៩

[40] មាត្រា ២៣៩. ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា. នស/រកម/១១០៩/០២២. ៣០ វិច្ឆិកា ២០០៩

[41] មាត្រា ១៦០. ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា. នស/រកម/១១០៩/០២២. ៣០ វិច្ឆិកា ២០០៩

[42] មាត្រា ៩៦. ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា. នស/រកម/០៨០៧/០២៤. ១០ សីហា ២០០៧

[43] មាត្រា ២១៣ និង ២១៤. ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា. នស/រកម/០៨០៧/០២៤. ១០ សីហា ២០០៧

ចំណែកឯការផ្តន្ទាទោសវិញ ក្រមព្រហ្មទណ្ឌបានធ្វើការកំណត់ដោយចាំបាច់ឲ្យបន្ថយមកត្រឹមពាក់កណ្តាលដោយមិនអាចអនុវត្តដូចអនុវត្តចំពោះនីតិជនឡើយ។

### ២.៣.២.អនីតិជនអាយុក្រោម ១៤ឆ្នាំ

អនីតិជន គឺជាជនដែលមានអាយុដែលច្បាប់កំណត់ថាជាជនដែលមិនទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ពីព្រោះគេជាជនដែលមិនអាចយល់ដឹងពីអំពើដែលខ្លួនបានប្រព្រឹត្តថា ជាបទល្មើសព្រហ្មទណ្ឌឡើយ ។ ការយល់ដឹងជាកត្តាមួយដ៏សំខាន់ដែលច្បាប់អាចកំណត់ពី ការទទួលខុសត្រូវរបស់បុគ្គលម្នាក់ៗ ដូច្នេះហើយអនីតិជនដែលមានអាយុក្រោម ១៤ឆ្នាំ មិនត្រូវបានទទួលខុសត្រូវព្រហ្មទណ្ឌឡើយ ។ ហើយបើទោះបីជាអនីតិជនមានអាយុក្រោម ១៤ឆ្នាំ មិនទទួលខុសត្រូវព្រហ្មទណ្ឌក៏ពិតមែន ប៉ុន្តែក៏នៅមានវិធានមួយចំនួនសម្រាប់អនុវត្តចំពោះអនីតិជនផងដែរ ។

វិធានការចំពោះការអនុវត្តចំពោះអនីតិជន ដែលប្រព្រឹត្តបទល្មើសជាកម្មវត្ថុនៃវិធានការតាមដាន វិធានការអប់រំ វិធានការការពារ និងវិធានការឧបត្ថម្ភ ដែលប្រភេទនៃវិធានការទាំងអស់នេះមានដូចតទៅ៖

១.ការប្រគល់អនីតិជនឲ្យឪពុកម្តាយ អាណាព្យាបាល បុគ្គលដែលថែរក្សាអនីតិជននោះ ឬបុគ្គលផ្សេងទៀតប្រសិនបើបុគ្គលនោះសក្តិសមទំនុកចិត្ត ។

២.ការប្រគល់អនីតិជនឲ្យទៅសេវាសាធារណៈដែលសម្រាប់ទទួលបន្ទុកអនីតិជន ។

៣.ការប្រគល់អនីតិជនឲ្យទៅអង្គការឯកជនដែលមាននីតិសម្បទានក្នុងការទទួលអនីតិជន ។

៤.ការប្រគល់អនីតិជនឲ្យទៅមន្ទីរពេទ្យ ឬស្ថាប័នឯកទេស ។

៥.ការដាក់អនីតិជនឲ្យស្ថិតនៅក្រោមការការពាររបស់តុលាការ[44]។

ការដាក់អនីតិជនឲ្យស្ថិតនៅក្រោមការការពារដោយតុលាការនោះ តុលាការចាត់តាំងបុគ្គលមួយរូបដែលទទួលបានភារៈធ្វើការតាមដានអនីតិជន។ បុគ្គលនេះធ្វើរបាយការណ៍ស្តីពីកិរិយាមារយាទរបស់ អនីតិជនឲ្យបានទៀងទាត់ដល់ព្រះរាជអាជ្ញា ។ បុគ្គលនេះផ្តល់ព័ត៌មានដល់ព្រះរាជអាជ្ញាអំពីព្រឹត្តិការណ៍ទាំងអស់ដែលអាចនាំឲ្យមានការកែប្រែនូវវិធានការនេះ។

មាត្រាទាំងពីរខាងលើបង្ហាញពីវិធានទាំងឡាយ ដែលសម្រាប់អនុវត្តទៅលើអនីតិជនក្នុងគោលបំណងអប់រំកែប្រែអនីតិជន ដែលបានប្រព្រឹត្តបទល្មើសឲ្យក្លាយជាបុគ្គលដ៏ល្អក្នុងសង្គមមិនតែប៉ុណ្ណោះ យើងមិនអាចផ្តន្ទាទោសណាមួយឡើយ ទោះបីជាអនីតិជននោះបានប្រព្រឹត្តបទល្មើសប្រភេទណាក៏ដោយមិនថាបទឧក្រិដ្ឋ ឬ បទមជ្ឈឹមឡើយ ។

[44] មាត្រា ៣៩ និង មាត្រា ៤០. ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា. នស/រកម/១១០៩/០២២. ៣០ វិច្ឆិកា ២០០៩

អនីតិជនដែលមានអាយុក្រោម ១៤ឆ្នាំ ពុំអាចត្រូវបានឃាត់ខ្លួនឡើយ[45] រីឯការឃុំខ្លួនបណ្តោះអាសន្នវិញ គឺមិនអាចអនុវត្តបានឡើយចំពោះអនីតិជនដែលមានអាយុក្រោម ១៤ឆ្នាំ[46]។

សរុបសេចក្តីមក អនីតិជន គឺជាជនដែលច្បាប់បានកំណត់ថា ជាជនដែលនឹងរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌ ប៉ុន្តែមានការកំណត់ជាពីរករណី គឺ អនីតិជនដែលមានអាយុចាប់ពី ១៤ ឆ្នាំ ដល់ក្រោមអាយុ ១៨ឆ្នាំ និងអនីតិជនដែលមានអាយុក្រោម ១៤ឆ្នាំ ។ នៅក្នុងនោះផងដែរចំពោះអនីតិជនដែលមានអាយុចាប់ពី ១៤ឆ្នាំ ដល់ក្រោមអាយុ ១៨ឆ្នាំ មានការទទួលខុសត្រូវព្រហ្មទណ្ឌទៅលើអំពើល្មើសដែលខ្លួនបានប្រព្រឹត្ត (បទឧក្រិដ្ឋ ឬ បទមជ្ឈិម) ដូចទៅនឹងនីតិជនធម្មតាដែរ ប៉ុន្តែចំពោះទោសទណ្ឌដែលមានវិញ គឺច្បាប់តម្រូវឲ្យតុលាការត្រូវពិនិត្យមើលទៅលើបុគ្គលិកលក្ខណៈ និង កាលៈទេសៈនៃបទល្មើសរបស់អនីតិជននោះតម្រូវ ហើយការអនុវត្តទោសនោះ គឺត្រូវកាត់បន្ថយមកត្រឹមពាក់កណ្តាលនៃ មូលទោស ។ ដោយឡែកបើចំពោះអនីតិជនដែលមានអាយុក្រោម ១៤ឆ្នាំ វិញ គឺគ្មានការទទួលខុសត្រូវលើរឿងព្រហ្មទណ្ឌនេះនោះទេ ប៉ុន្តែច្បាប់យើងបានចាត់បញ្ចូលវិធានការមួយចំនួនវិញ ដើម្បីជំនួសពីការមិនទទួលខុសត្រូវនេះ ដែលវិធានទាំងនោះមានដូចជា៖ វិធានការតាមដាន វិធានការអប់រំ វិធានការការពារ និងវិធានការឧបត្ថម្ភជាដើម ក្នុងគោលបំណងធ្វើការអប់រំកែប្រែអនីតិជននោះឲ្យក្លាយទៅជាបុគ្គលដែលជាពលរដ្ឋល្អក្នុងសង្គម ដើម្បីកុំឲ្យប្រព្រឹត្តខុសនៅថ្ងៃខាងមុខតទៀត ។ បន្ថែមពីនេះទៀត បញ្ញាត្តិនៃក្រមព្រហ្មទណ្ឌស្តីពីការមិនរាងចាល មិនអាចយកមកអនុវត្តបានឡើយចំពោះអនីតិជន បើទោះបីជាអនីតិជននោះបានប្រព្រឹត្តក្នុងស្ថានភាពមិនរាងចាលក៏ដោយ[47]។

[45] មាត្រា ៩៦. ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា. នស/រកម/០៨០៧/០២៤. ១០ សីហា ២០០៧

[46] មាត្រា ២១២. ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា. នស/រកម/០៨០៧/០២៤. ១០ សីហា ២០០៧

[47] មាត្រា ១៦៣. ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា. នស/រកម/១១០៩/០២២. ៣០ វិច្ឆិកា ២០០៩

# ជំពូកទី៣
# បណ្តាករណីដទៃផ្សេងទៀត

បណ្តាករណីដទៃផ្សេងទៀត ជាបណ្តាករណីដែលត្រូវបានចាត់ទុកថាជាមូលហេតុដែលរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌផងដែរ ។ បណ្តាករណីទាំងនោះមិនមាននៅក្នុងបណ្តាបញ្ញត្តិនៅក្នុងក្រមព្រហ្មទណ្ឌ ដូចមូលហេតុទាំងពីរដែលបានរៀបរាប់ខាងលើឡើយ (យុត្តិកម្មនៃបទល្មើស និង ភាពមិនអាចទម្លាក់កំហុសបាន) ប៉ុន្តែវាជាករណីដែលច្រើនតែជួបប្រទះក្នុងជីវភាពប្រចាំថ្ងៃ ហើយក៏ជាការអនុវត្តជាប្រចាំផងដែរ។ តើករណីណាខ្លះដែលត្រូវបានចាត់ទុកថាជាមូលហេតុដែលរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌ ហើយករណីណាខ្លះទៀតដែលជាការភាន់ច្រឡំ ។ ការភាន់ច្រឡំនេះអាចជាមូលហេតុដែលរួចផុតពីការទទួលខុសត្រូវដែរ ឬយ៉ាងណា។

## ៣.១.ការភាន់ច្រឡំ និង ឥទ្ធិពលនៃការទទួលខុសត្រូវ

ជាទូទៅ គេតែងតែយល់ថា គ្រប់ការភាន់ច្រឡំទាំងអស់មិនអាចមានការទទួលខុសត្រូវព្រហ្មទណ្ឌឡើយ ក៏ប៉ុន្តែការភាន់ច្រឡំនៅក្នុងករណីខ្លះគឺមានការការទទួលខុសត្រូវនៅចំពោះមុខច្បាប់ជាធរមាន ។ ការភាន់ច្រឡំត្រូវបានស្តែងចេញក្នុងធាតុអត្តនោម័តនៃបទល្មើស (ធាតុចិត្ត) ហើយតាមរយៈទ្រឹស្តី ការភាន់ច្រឡំត្រូវបានបែងចែកជាពីរគឺ ការភាន់ច្រឡំអំពីអង្គច្បាប់ និង ការភាន់ច្រឡំអំពីអង្គហេតុ ។ ការភាន់ច្រឡំជាការយល់ច្រឡំរបស់ជនល្មើស អំពីអត្ថន័យគតិយុត្តិ ឬ បណ្តាស្ថានភាពជាក់ស្តែងរបស់អំពើដែលគេប្រព្រឹត្ត[48]។

### ៣.១.១.ការភាន់ច្រឡំអំពីអង្គច្បាប់

ការភាន់ច្រឡំអំពីអង្គច្បាប់ គឺជាការភាន់ច្រឡំរបស់បុគ្គលម្នាក់ចំពោះច្បាប់ដែលមានអនុភាពគតិយុត្តិ (ក្រមព្រហ្មទណ្ឌ) អំពីអំពើដែលមានចរិតផ្ទុយច្បាប់ដែលខ្លួនប្រព្រឹត្ត ។ ការភាន់ច្រឡំនេះស្តែងចេញជាពីរ ករណីគឺ ការប្រព្រឹត្តដោយជាក់លាក់ ឬ ស្មាន និង ការប្រព្រឹត្តអំពើដោយយល់ច្រឡំ។

#### ៣.១.១.១.ការប្រព្រឹត្តអំពើដោយជាក់លាក់ ឬ ស្មាន

បុគ្គលម្នាក់បានប្រព្រឹត្តអំពើមួយដែលខ្លួនគិតថា មិនមែនជាបទល្មើស ឬ ស្មានថាទង្វើដែលខ្លួនកំពុងតែប្រព្រឹត្តមិនត្រូវបានចាត់ទុកថាជាបទល្មើស ក៏ប៉ុន្តែតាមពិតអំពើ ឬ ទង្វើនោះត្រូវបានច្បាប់បញ្ញត្តិថាជាបទល្មើស ។ ការភាន់ច្រឡំនេះមានចរិតលក្ខណៈគ្រោះថ្នាក់ដល់សង្គម មិនតែប៉ុណ្ណោះជនដែលប្រព្រឹត្តបទល្មើសនោះ បើទោះបីជាអំពើនោះកើតឡើងដោយការភាន់ច្រឡំក៏ដោយក៏ត្រូវតែទទួលខុសត្រូវព្រហ្មទណ្ឌដែរ ពោលគឺ បុគ្គលនោះមិនអាចរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌបាននោះឡើយចំពោះការភាន់ច្រឡំនេះ ។ **ឧទាហរណ៍:** ក បានដាំដើមអាភៀនជាច្រើនដើមក្នុងចំការរបស់គាត់ ដោយយល់ថាវាលក់បានថ្លៃ ម្យ៉ាងវិញទៀតខ្លួនបានគិតថាការដាំអាភៀន

[48] ជួន ប៊ុនធី នីតិព្រហ្មទណ្ឌទូទៅ

ប៉ុណ្ណឹងមិនមែនជាអំពើល្មើសច្បាប់ឡើយ ពីព្រោះការដាំនេះមិនមែនជាការដាំជាលក្ខណៈទ្រង់ទ្រាយធំ ដែលខ្លួនដាំនេះគឺដាំជាលក្ខណៈគ្រួសារ ។ នៅពេលដែល ក កំពុងប្រមូលផលក៏ត្រូវបានប៉ូលីសចាប់ឃាត់ខ្លួន ។ ថ្វីត្បិតតែ ក ស្មានថាការដាំអាភៀនមិនមែនជាបទល្មើស និងមិនត្រូវបានច្បាប់ហាមឃាត់ ក៏ប៉ុន្តែតាមការពិតការដាំអាភៀននេះ ត្រូវបានច្បាប់ចាត់ទុកថាជាបទល្មើសទៅហើយ ដូចនេះ ក ត្រូវតែទទួលខុសត្រូវចំពោះមុខច្បាប់ បើទោះបីជាបទល្មើសកើតឡើងដោយការភាន់ច្រឡំក៏ដោយ[49]។

### ៣.១.១.២.ការប្រព្រឹត្តអំពើយល់ច្រឡំ

បុគ្គលម្នាក់បានប្រព្រឹត្តអំពើ ដែលខ្លួនគិតថាច្បាប់ព្រហ្មទណ្ឌបញ្ញត្តិថាជាបទល្មើស ប៉ុន្តែការជាក់ស្តែង អំពើនោះមិនត្រូវបានច្បាប់បញ្ញត្តិថាវាជាបទល្មើសនោះឡើយ ដែលនៅក្នុងនោះដូចជាមានការការពារធម្មានុរូបជាដើម ។ ដែលការភាន់ច្រឡំនេះ មិនមានចរិតលក្ខណៈគ្រោះថ្នាក់ដល់សង្គមនោះឡើយ ហើយករណីនេះក៏មិនត្រូវបានចាត់ចូលថាជាបទល្មើសនោះដែរ ដែលវាគ្រាន់តែជាការទប់ស្កាត់នូវរាល់អំពើណាមួយដែលមានការបំពាន ។ **ឧទាហរណ៍:** ក បានចតឡាននៅលើផ្លូវដើម្បីចូលទៅទិញឥវ៉ាន់នៅក្នុងផ្សារ ។ ក្រោយពលចូលទៅ បានមួយសន្ទុះ ក គិតថាខ្លួនបានចតឡាននៅលើផ្លូវដែលត្រូវបានគេហាមឃាត់ តែដោយសារតែខ្លួនមិនបានឃើញស្លាកសញ្ញាហាមឃាត់មិនឲ្យចត ។ ករណីនេះ ក មិនត្រូវទទួលខុសត្រូវ ហើយក៏មិនចាត់ទុកថាជាបទល្មើសនោះដែរ ពីព្រោះថា ការប្រព្រឹត្តរបស់ ក មកពិការមិនបានឃើញនូវស្លាកសញ្ញាហាមចតនោះ ។

### ៣.១.២.ការភាន់ច្រឡំអំពីអង្គហេតុ

ការភានច្រឡំអំពីអង្គហេតុ គឺជាការភាន់ច្រឡំរបស់ជនម្នាក់អំពីបណ្តានៃស្ថានភាពជាក់ស្តែងអំពីអំពើរបស់ខ្លួន ហើយពុំមែនគ្រប់ការភាន់ច្រឡំជាក់ស្តែងណា ក៏មានឥទ្ធិពលដល់ការទទួលខុសត្រូវព្រហ្មទណ្ឌនោះទេ គឺមានតែការភាន់ច្រឡំ អំពីបណ្តាកត្តារួមផ្សំបទល្មើសតែប៉ុណ្ណោះទើបមានឥទ្ធិពលដល់ការទទួលខុសត្រូវព្រហ្មទណ្ឌ ។ ខាងក្រោមនេះជាការភាន់ច្រឡំទាំងឡាយដែលពាក់ព័ន្ធនឹងការភាន់ច្រឡំអំពីអង្គហេតុរបស់ចារីះ

### ៣.១.២.១.ការភាន់ច្រឡំកម្មវត្ថុ

កម្មវត្ថុនៅទីនេះសំដៅដល់កម្មវត្ថុនៃបទល្មើស មានន័យថាជនល្មើសពុំបានយល់ឲ្យត្រឹមត្រូវ អំពីអំពើដែលខ្លួនកំពុងបង្កឲ្យមានការអន្តរាយជាក់ស្តែង ។ ភាន់ច្រឡំកម្មវត្ថុត្រូវបានបែងចែកចេញជា ៤ចំណុចធំៗគឺះ

- ជនល្មើសមានបំណងគិតនឹងបំពានទៅលើកម្មវត្ថុដែលមានសារៈសំខាន់ ប៉ុន្តែនៅពេលដែលប្រព្រឹត្តជាក់ស្តែង បែរជាបំពានដល់កម្មវត្ថុដែលមានសារៈសំខាន់តិច

[49] មាត្រា ២ និង មាត្រា ៥. ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន. នស/រកម/០១១២/០០១. ០២ មករា ២០១២

ជាងកម្មវត្ថុដែលខ្លួនមានបំណងបំពានទៅវិញ ។ **ឧទាហរណ៍:** ក មានបំណងចង់លួចទ្រព្យសម្បត្តិរបស់រដ្ឋ ប៉ុន្តែជាក់ស្តែងបែរជាលួចទ្រព្យសម្បត្តិរបស់ឯកជន ដែលមាន លក្ខណៈស្រដៀងទៅនឹងទ្រព្យសម្បត្តិរបស់រដ្ឋទៅវិញ ។ ករណីនេះជនល្មើសត្រូវតែទទួលខុសត្រូវព្រហ្មទណ្ឌ ដោយទទួលខុសត្រូវអំពីបទល្មើសដែលមានកម្មវត្ថុដូច ដែលខ្លួនមានបំណងថានឹងបំពាន។ **ឧទាហរណ៍:** ក មានបំណងចង់លួចទ្រព្យសម្បត្តិ ពោលគឺឆក់កាបូប ប៉ុន្តែបានធ្វើឲ្យរងគ្រោះស្លាប់ដោយសារដួលប៉ះក្បាលទៅនឹងចិញ្ចើមថ្នល់ ។ ជនល្មើសត្រូវតែទទួលខុសត្រូវ ចំពោះបទល្មើសលួចមានស្ថានទម្ងន់ទោសដោយសារមរណភាពនៃជនរងគ្រោះ ប្រសិនបើគេរកឃើញថាជនល្មើសគ្មានបំណងសម្លាប់ជនរងគ្រោះ ។

- ជនល្មើសមានបំណងគិតនឹងបំពានទៅលើកម្មវត្ថុច្រើន ប៉ុន្តែនៅពេលដែលប្រព្រឹត្តជាក់ស្តែង បែរជាបំពានដល់កម្មវត្ថុតែមួយទៅវិញ ។ **ឧទាហរណ៍:** ក មានបំណងចង់លួចទ្រព្យសម្បត្តិរបស់រដ្ឋផង និងទ្រព្យសម្បត្តិរបស់ឯកជន ប៉ុន្តែជាក់ស្តែងបែរជាលួចបានត្រឹមតែទ្រព្យសម្បត្តិរបស់ឯកជនតែប៉ុណ្ណោះ ។ ករណីនេះជនល្មើសត្រូវតែទទួលខុសត្រូវចំពោះបទល្មើសដែលខ្លួនបានប្រព្រឹត្ត ពោលគឺ ជនល្មើសត្រូវទទួលខុសត្រូវចំពោះបទល្មើសដែលមានកម្មវត្ថុចំពោះអ្វីដែលខ្លួនបានបំពានតែប៉ុណ្ណោះ ។
- ជនល្មើសបានប្រព្រឹត្តអំពើដែលខ្លួនគិតថា មិនបានបំពានលើកម្មវត្ថុដែលក្រមព្រហ្មទណ្ឌបានការពារ តែការជាក់ស្តែងជនល្មើសបានបំពានដល់កម្មវត្ថុ ដែលក្រមព្រហ្មទណ្ឌបានការពារ ។ **ឧទាហរណ៍:** ក បានបាញ់បុរសម្នាក់ស្លាប់ដោយភាន់ច្រឡំថាជាជាសត្វដែលនៅលើដើមឈើក្នុងព្រៃ។ ករណីនេះជនល្មើសត្រូវតែទទួលខុសត្រូវចំពោះការស្លាប់របស់បុរសម្នាក់នោះ ដោយជាបទមនុស្សឃាតដោយអចេតនាក្នុងករណីដែលគេរកឃើញថាកើតឡើងពីកំហុសអចេតនា ។

### ៣.១.២.២.ការភាន់ច្រឡំមុខសញ្ញា

ការភាន់ច្រឡំមុខសញ្ញា គឺជាការភាន់ច្រឡំរបស់ជនម្នាក់ទៅលើមុខសញ្ញានៃបទល្មើស ពោលគឺ ការភាន់ច្រឡំទៅលើមុខសញ្ញាក្នុងពេលដែលជននោះប្រព្រឹត្តបទល្មើស ។ ការភាន់ច្រឡំមុខសញ្ញា ក៏ជាមូលហេតុដែលត្រូវទទួលខុសត្រូវព្រហ្មទណ្ឌផងដែរ ។ **ឧទាហរណ៍:** ក គិតចង់សម្លាប់ ខ ប៉ុន្តែពេលប្រព្រឹត្តបទល្មើសជាក់ស្តែងនោះបែរជាសម្លាប់ចំ គ ទៅវិញដោយសារតែច្រឡំ គ ជា ខ ។ ក្នុងករណីនេះទោះបីជាមានការភាន់ច្រឡំមុខសញ្ញាបែបនេះក៏ដោយ ក៏ការភាន់ច្រឡំនេះមិនអាចជាមូលហេតុមួយសម្រាប់យកមកអះអាងបានឲ្យជន ដែលបានប្រព្រឹត្តនោះរួចផុតពីការទទួលខុសត្រូវនូវរាល់អំពើដែលខ្លួនបានប្រព្រឹត្តនោះឡើយ ដូចនេះ ក ត្រូវតែទទួលខុសត្រូវចំពោះ

មុខច្បាប់ជាធរមាន ។ ម្យ៉ាងវិញទៀតបើទោះបីជាអ្នកស្លាប់មិនមែនជាមុខសញ្ញាពិតប្រាកដរបស់ជនល្មើសក៏ដោយ ប៉ុន្តែចរិតលក្ខណៈនៃអំពើរបស់ជនល្មើសក្នុងការសម្លាប់មនុស្សវាជាកំហុសព្រហ្មទណ្ឌទៅហើយ ។ ហើយករណីប្រភេទនេះមិនមែនមានតែការភាន់ច្រឡំរបស់ជនល្មើសនោះទេ ប៉ុន្តែនៅមានការភាន់ច្រឡំអំពីការការពាខ្លួនផងដែរ ការភាន់ច្រឡំបែបនេះ វាគឺជាការភាន់ច្រឡំរបស់មនុស្សដែលការពារខ្លួនពីការបំពាន ប៉ុន្តែការប្រើប្រាស់នូវការការពារខ្លួននេះបែរជាធ្វើឲ្យតតិយជនរងរបួស ដោយសារតែខ្លួនបានយល់ច្រឡំថាតតិយជននោះគឺជាអ្នកដែលប្រព្រឹត្តអំពើបំពានមកលើរូបខ្លួន ។ **ឧទាហរណ៍៖** ផ្ទះរបស់ស្ត្រី **ក** ត្រូវបានចោរចូលលួចតវ៉ាន់ជារៀងរាល់យប់ ។ នៅវេលាយប់មួយមានបុរសម្នាក់បានចូលទៅក្នុងផ្ទះ **ក** នៅពេលយប់ ហេតុនេះហើយស្ត្រីនោះក៏បានវាយទៅលើបុរសម្នាក់នោះរហូតមានរបួសធ្ងន់ធ្ងរ ដោយគិតថាបុរសនោះគឺជាអ្នកលួចតវ៉ាន់របស់ខ្លួន ប៉ុន្តែដោយតាមការពិតទៅបុរសនោះគ្រាន់តែចូលទៅ ដើម្បីសួរនាំស្ត្រីនោះតែប៉ុណ្ណោះ។ ករណីនេះស្ត្រីម្នាក់នោះមិនបានរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌឡើយ បើនោះបីជាមានការភាន់ច្រឡំក៏ដោយ និងដោយតាមការពិតទៅនេះគ្រាន់តែជាការការពារដោយភាន់ច្រឡំរបស់បុគ្គលម្នាក់តែប៉ុណ្ណោះ ។

**៣.១.២.៣.ការភាន់ច្រឡំមធ្យោបាយ**

ការភាន់ច្រឡំមធ្យោបាយ ជាការភាន់ច្រឡំមួយបែបទៀតដែលស្តែងឡើងនៅត្រង់ពេលដែលជនល្មើសគិតថានឹងប្រើប្រាស់មធ្យោបាយណាមួយ ក្នុងការប្រព្រឹត្តបទល្មើសដើម្បីឈានទៅដល់គោលដៅដែលខ្លួនចង់បាន ប៉ុន្តែដោយសារការភាន់ច្រឡំបែបជាប្រើប្រាស់មធ្យោបាយ ដែលស្ថិតនៅក្រៅការគិតរបស់ខ្លួនទៅវិញ ។ **ឧទាហរណ៍:** ក បានប្រើប្រាស់កាំភ្លើងជាអាវុធក្នុងការសម្រេចនូវគោលដៅសម្លាប់មនុស្សដែលខ្លួនចង់សម្លាប់ ប៉ុន្តែបែរជាយកចំកាំភ្លើងចាស់បាញ់មិនចេញគ្រាប់ទៅវិញ ។ ក្នុងករណីនេះ ឆន្ទៈរបស់ជនល្មើសគឺចង់បាញ់សម្លាប់មនុស្សដែលខ្លួនចង់សម្លាប់ទៅតាមគោលបំណង និងមធ្យោបាយដែលខ្លួនបានគិត បើទោះបីជាការបាញ់មិនចេញ ឬ ក៏មូលហេតុណាមួយក៏ដោយ ឲ្យតែតុលាការរកឃើញថាជននោះមានចេតនាសម្លាប់ហើយ ទោះជាមិនបានសម្រេចក៏បុគ្គលនោះត្រូវតែទទួលខុសត្រូវនូវរាល់អ្វីដែលខ្លួនបានប្រព្រឹត្ត បានន័យថាជននោះនឹងត្រូវទទួលខុសត្រូវនូវរាល់អ្វីដែលខ្លួនបានប្រព្រឹត្ត ។

**៣.១.២.៤.ការភាន់ច្រឡំពីទំនាក់ទំនងហេតុផល**

ការភាន់ច្រឡំពីទំនាក់ទំនងហេតុផល គឺជាការភាន់ច្រឡំដែលជនល្មើសមិនអាចវាយតម្លៃឲ្យបានត្រឹមត្រូវនូវបច្ច័យដែលកើតឡើងដោយសារទង្វើររបស់ខ្លួន ។ **ឧទាហរណ៍:** ជនម្នាក់គ្មានបទពិសោធន៍គ្រប់គ្រាន់ក្នុងការបើករថយន្ត បានទៅបើករថយន្តក្នុងល្បឿនលឿនហើយគ្មានការប្រុងប្រយ័ត្នបណ្តាលឲ្យជ្រុលចង្កូតទៅបុកអ្នកដំណើរតាមដងផ្លូវរងរបួសធ្ងន់ ។ ការភាន់ច្រឡំកើតឡើង

ដោយសារការមិនបានពិនិត្យឲ្យបានច្បាស់លាស់នូវលទ្ធផល ដែលកើតមកពីការជឿទុកចិត្តលើខ្លួនឯងពេកថា ខ្លួនអាចធ្វើបាន ប៉ុន្តែតាមការពិតខ្លួនឯងពិតជាគ្មាននូវសមត្ថភាពគ្រប់គ្រាន់ដូចអ្វីដែលខ្លួនបានគិតទុក ។ ដូច្នេះ ជននោះត្រូវតែទទួលខុសត្រូវព្រហ្មទណ្ឌអំពីកំហុសអចេតនា។

រាល់ករណីទាំងអស់នៃការភាន់ច្រឡំ គឺសុទ្ធតែកើតចេញពីកំហុសអចេតនាទាំងអស់របស់ជនល្មើស ។

## ៣.២.ផលប៉ះពាល់នៃផលិតកម្មស្រាវជ្រាវអំពីវិទ្យាសាស្ត្រ

ជាធម្មតាក្នុងការរស់នៅ និងជីវភាពប្រចាំថ្ងៃ គឺតែងតែតម្រូវឲ្យមាននូវការទទួលយកនូវគំនិត និងការកែច្នៃថ្មីៗ ដើម្បីយកទៅបង្កើតទិន្នផលខាងផ្នែកពលកម្ម គុណភាពនៃផលិតផល លទ្ធផលនៃការផលិត និងការរីកចំរើនខាងផ្នែកវិទ្យាសាស្ត្រ ដែលបានបម្រើដល់ផលប្រយោជន៍រួម និងដើម្បីឆ្លើយតបទៅនឹងតម្រូវការក្នុងសង្គម ក៏ប៉ុន្តែដំណាក់ការនៃការរុករក ការកែច្នៃផលិតកម្មស្រាវជ្រាវវិទ្យាសាស្ត្រ មានករណីខ្លះអាចនឹងបង្កឲ្យមានការអន្តរាយដល់ផលប្រយោជន៍ក្នុងសង្គម។ នីតិវិទ្យានៃផ្នែកព្រហ្មទណ្ឌបានធ្វើការលើកឡើងថា ប្រសិនបើសកម្មភាពស្រាវជ្រាវ ការកែច្នៃ ការប្រើប្រាស់នូវភាពជឿនលឿននៃវិទ្យាសាស្ត្រ ដើម្បីជាផលប្រយោជន៍របស់សង្គមមួយដែលមានការអភិវឌ្ឍ ហើយបានប្រតិបត្តិតាមឲ្យខានតែបាននូវបទបញ្ញា និងសំណូមពរ អំពីសុវត្ថិភាព ដែលត្រូវបានកំណត់ ប៉ុន្តែករណីខ្លះដោយសារបាតុភូតក្រៅពីការយល់ដឹងរបស់មនុស្ស និងគ្មានលទ្ធភាពទប់ទល់របស់អ្នកស្រាវជ្រាវ អ្នកផលិតបានបង្កឲ្យមានការអន្តរាយកើតឡើងដល់សង្គម នោះពួកគេមិនត្រូវបានទទួលខុសត្រូវព្រហ្មទណ្ឌឡើយ ។ ករណីដែលអ្នកជំនាញព្រហ្មទណ្ឌធ្វើបែបនេះព្រោះថា ដើម្បីលើកទឹកចិត្តដល់ អ្នកស្រាវជ្រាវ និងក្មេងៗជំនាន់ថ្មីនៅក្នុងការស្រាវជ្រាវ និងជំរុញដល់ការច្នៃប្រឌិតឲ្យបានកាន់តែប្រសើរឡើងពីមួយជំនាន់ទៅមួយជំនាន់ទៀត ។

## ៣.៣.ផលប៉ះពាល់នៃភារអនុវត្តភារកិច្ចក្នុងមុខជំនាញ

នីតិវិទ្យានៃនីតិព្រហ្មទណ្ឌ ពុំចាត់ទុកអំពើដែលបង្កឲ្យមានការអន្តរាយដល់បុគ្គលផ្សេងដោយសារការបំពេញភារកិច្ចក្នុងមុខជំនាញ មិនមែនជាការទទួលខុសត្រូវព្រហ្មទណ្ឌឡើយ ។ ប្រសិនបើពិនិត្យអំពីការងារជំនាញយើងសង្កេតឃើញថា ចាំបាច់ត្រូវតែបានទទួលការយល់ព្រម និង ដើម្បីជាប្រយជន៍របស់ជនរងគ្រោះ ឬ ដើម្បីជាប្រយោជន៍របស់សង្គម ។ ករណីនេះច្រើនកើតឡើងចំពោះគ្រូពេទ្យដែលមានបំណងចង់ស្រោចស្រង់ក៏ដូចជាជួយសង្គ្រោះដល់អាយុជីវិត និង សុខភាពរបស់អ្នកជំងឺដោយចាំបាច់ត្រូវបង្កឲ្យមានការឈឺចាប់លើផ្នែកណាមួយនៃរូបរាងកាយ ហើយមានពេលខ្លះអាចឈានទៅដល់ការវះកាត់អវៈយវៈណាមួយរូបរាងកាយ ។ ការវះកាត់អវៈយវៈរបស់គ្រូពេទ្យនេះ បើទោះបីជាបង្កឲ្យមានព្យសនកម្មដល់បូរណភាពរូបរាងកាយក៏ដោយ ក៏ប៉ុន្តែវាជាការជួយសង្គ្រោះក្នុងន័យស្រោចស្រង់ដល់អាយុជីវិតអ្នកជំងឺ ។ម្យ៉ាងទៀតអ្នកប្រព្រឹត្តអំពើនេះក៏មានការព្រមព្រៀងជាមុន

ដែរ មិនមែនជាចេតនាទុច្ចរិតណាមួយក្នុងការបង្កឲ្យមានព្យសនកម្មដល់បូរណភាពរូបរាងកាយបុគ្គលដែរ ។ **ឧទាហរណ៍:** អ្នកជំងឺម្នាក់មានជម្ងឺជាទំងន់ដែលតម្រូវឲ្យមានការវះកាត់តែការវះកាត់អាចធ្វើឲ្យអ្នកជម្ងឺរស់ ឬ ស្លាប់ ។ ក្នុងករណីនេះវេជ្ជបណ្ឌិតអាចសម្រេចធ្វើការវះកាត់បាន លុះត្រាតែមានការព្រមព្រៀងរវាងអ្នកជម្ងឺ ឬ ក្រុមគ្រួសាររបស់អ្នកជម្ងឺ ជាមួយវេជ្ជបណ្ឌិតជំនាញក្នុងការវះកាត់លើបុគ្គលដែលជាអ្នកជម្ងឺនោះ ទើបអាចដំណើរការវះកាត់នោះបាន ។ ក្នុងករណីខ្លះដែលកំពុងវះកាត់ ស្រាប់តែជួបនឹងគ្រោះថ្នាក់ដល់ជីវិតអ្នកជំងឺ ពោលគឺ អ្នកជំងឺត្រូវបានស្លាប់ដោយសារការវះកាត់ខាងលើនេះ។ ព្យសនកម្មបែបនេះពុំមានទំនាក់ទំនងនឹង អំពើរបស់ក្រុមវេជ្ជបណ្ឌិតឡើយ ដូច្នេះក៏មិនអាចចាត់ទុកថាជាបទល្មើសបានឡើយ ពីព្រោះថាអំពើរបស់វេជ្ជបណ្ឌិតនោះបានស្តែងឡើងដោយចេតនាសុចរិតមនុស្សធម៌យ៉ាងពិតប្រាកដ ដែលទង្វើបែបនេះត្រូវបានច្បាប់ចាត់ទុកថាមូលហេតុដែលរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌ ។

## ៣.៤.ការយល់ព្រមពីសំណាក់ជនរងគ្រោះ

ការព្រមព្រៀងពីសំណាក់ជនរងគ្រោះ ត្រូវបានគេឃើញជាញឹកញាប់ក្នុងជីវភាពរស់នៅប្រចាំថ្ងៃដោយក្នុងនោះបានស្តែងចេញជាបណ្តាករណីដូចខាងក្រោម៖

### ៣.៤.១.ការព្រមព្រៀងពីជនរងគ្រោះ

ចំពោះអំពើល្មើសខ្លះចាំបាច់ត្រូវតែមានការប្តឹងពីសំណាក់ជន រងគ្រោះជាមុនសិនទើបអាចធ្វើការចោទប្រកាន់ថាជាបទល្មើសបាន ។ ប្រសិនបើគ្មានការប្តឹងចោទប្រកាន់ពីសំណាក់ជនរងគ្រោះទេនោះ អំពើល្មើសនោះនឹងមិនត្រូវបានចាត់ទុកថាជាបទល្មើសឡើយ ដូច្នេះគេចាត់ទុកថាជាការព្រមព្រៀង ។ ចាត់ទុកថាជាការព្រមព្រៀង លុះត្រាតែ៖

- ការព្រមព្រៀងត្រូវកើតមុន ឬ ដំណាលគ្នាជាមួយអំពើប្រព្រឹត្ត មានន័យថាបើមានវត្តមាននៃការព្រមព្រៀងរបស់ជនរងគ្រោះបានកើតមុន ឬ ដំណាលគ្នាជាមួយអំពើប្រព្រឹត្តនោះ ពោលគឺ បើមុនពេលប្រព្រឹត្តអំពើគ្មានវត្តមាននៃការព្រមព្រៀងទេ អំពើនោះនឹងក្លាយទៅជាបទល្មើស ប៉ុន្តែបើមានការព្រមព្រៀងនោះនឹងមិនអាចក្លាយជាបទល្មើសឡើយ ។ **ឧទាហរណ៍:** នារីម្នាក់បានព្រមព្រៀងជាមួយបុរសម្នាក់ថានឹងរួមដំណេកជាមួយគ្នា ។ វត្តមាននៃការព្រមព្រៀងនេះមិនអាចចោទប្រកាន់បុរសនោះថាប្រព្រឹត្តបទល្មើសរំលោភសេពសន្ថវៈឡើយ ។
- ការព្រមព្រៀងកើតក្រោយអំពើប្រព្រឹត្ត មានន័យថាជនរងគ្រោះគ្មានការប្តឹងទៅមន្ត្រីនគរបាលយុត្តធម៌ ឬ ស្ថាប័នអយ្យការពីបទល្មើសនោះឡើយ ។ ប្រសិនបើគ្មានការប្តឹងពីសំណាក់ជនរងគ្រោះទេ នោះច្បាប់នឹងចាត់ទុកអំពើល្មើសដែលប្រព្រឹត្តមកលើ

ជនរងគ្រោះថាពុំមែនជា បទល្មើសឡើយ ។ **ឧទាហរណ៍:** បទទ្វេពន្ធភាព អំពើហឹង្សាក្នុងគ្រួសារជាដើម ។

### ៣.៤.២.ការបំពេញតាមសំណូមពរជនរងគ្រោះ

ចំពោះអំពើល្មើសខ្លះត្រូវបានកើតឡើង ដោយសារតែការបំពេញតាមសំណូមពររបស់ជនរងគ្រោះ ដូច្នេះអ្នកប្រព្រឹត្តអំពើល្មើសនេះមិនត្រូវបានទទួលខុសត្រូវព្រហ្មទណ្ឌឡើយ។ វាជាទ្រឹស្តីមួយដែលត្រូវបានគេយកមកស្រាវជ្រាវសម្រាប់ជាការអនុវត្តនូវទ្រឹស្តីនេះ ក្នុងសង្គមនាពេលបច្ចុប្បន្ននេះ ហើយទ្រឹស្តីនេះផ្តើមចេញពីកត្តាមនុស្សធម៌ ។ **ឧទាហរណ៍:** ករណីអ្នកជម្ងឺម្នាក់មានជម្ងឺមួយប្រភេទដែលមិនអាចព្យាបាលបាន រស់នៅដោយពឹងផ្អែកលើការប្រើប្រាស់ថ្នាំ និងឧបករណ៍វេជ្ជសាស្ត្រទំនើបៗ ។ ដោយមិនអាចទ្រាំនឹងការឈឺចាប់បានក៏សំណូមពរឲ្យចាក់ថ្នាំបញ្ចប់ជីវិតខ្លួនឯង ។

សរុបសេចក្តីមក បណ្តាមូលហេតុទាំងឡាយដែលបានយកមកបង្ហាញខាងលើ គឺចង់បញ្ជាក់ឲ្យច្បាស់នូវមូលហេតុដែលរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌ និង ការទទួលខុសត្រូវព្រហ្មទណ្ឌដែលកើតចេញពីការភាន់ច្រឡំ ឬ ការអនុវត្តផ្ទាល់នៅក្នុងសង្គមឲ្យកាន់តែច្បាស់លាស់បន្ថែមទៀត ចៀសវាងការបរព្រឹត្តខុសដោយមិនបានដឹងថាវាជាបទល្មើសដែលបញ្ញត្តិដោយក្រមព្រហ្មទណ្ឌ ។

# សេចក្តីសន្និដ្ឋាន

មានមនុស្សជាច្រើនដែលរស់នៅក្នុងសង្គម ហើយមនុស្សទាំងអស់នោះគឺបានកើតឡើងព្រមជាមួយសិទ្ធិ និងកាតព្វកិច្ចរបស់ពួកគេជាច្រើន ដែលទទួលបានពីច្បាប់របស់ប្រទេសរៀងៗខ្លួន ហេតុនេះហើយទើបធ្វើឲ្យមនុស្សម្នាក់ៗលោភលន់ទៅនឹងសិទ្ធិអំណាចដែលខ្លួនមាន ប្រើប្រាស់សិទ្ធិរបស់ខ្លួនបំពានទៅលើសិទ្ធិអ្នកដ៏ទៃ ធ្វើឲ្យសង្គមគ្មានសណ្តាប់ធ្នាប់ បាត់បង់របៀបរៀបរយនៅក្នុងសង្គម ដូចនេះទើបក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានបង្កើតឡើង ដើម្បីធ្វើការធានាឲ្យបាននូវការប្រើប្រាស់សិទ្ធិ ដែលបុគ្គលម្នាក់ៗមាន មិនឲ្យមានការបំពានទៅដល់បុគ្គលម្នាក់ផ្សេងទៀត ដោយមិនលើកលែងថាបុគ្គលនោះមានចេតនាក្តី ឬ ក៏គ្មានចេតនាក្តី ។ មិនត្រឹមតែជាការកម្រឹតនូវសិទ្ធតែប៉ុណ្ណោះទេ ប៉ុន្តែក្រមព្រហ្មទណ្ឌនេះក៏បានបង្កើតឲ្យមានការការពារស្របច្បាប់មួយដែលបុគ្គលម្នាក់ៗអាចប្រើវាបានដើម្បីទប់ស្កាត់ ហាមឃាត់ រុញច្រាន ឬ ធ្វើការបង្អាក់កុំឲ្យមានការបំពានមួយកើតមានឡើងដោយប៉ះពាល់ដល់បូរណភាពរូបរាងកាយ ទ្រព្យសម្បត្តិផ្សេងៗដែលទទួលបានការការ ពារដោយច្បាប់ជាធរមាន ហើយម្យ៉ាងវិញទៀតច្បាប់នេះក៏បានបង្កើតឡើង ក្នុងគោលបំណងការពារទៅនឹងអំពើទាំងឡាយណាដែលនឹង បង្កឲ្យមានគ្រោះថ្នាក់ និងការអន្តរាយដល់សង្គម និងបង្កើតឲ្យបុគ្គលម្នាក់ ដែលបានប្រព្រឹត្តអំពើនោះត្រូវតែទទួលខុសត្រូវនៅចំពោះមុខច្បាប់នូវរាល់អ្វីដែលខ្លួនបានប្រព្រឹត្ត។ ថ្វីបើទោះបីជាមានការកម្រិត និងកំណត់បែបអំពីសិទ្ធិ ការទទួលខុសត្រូវ ឬក៏ទណ្ឌកម្មបែបនេះដោយច្បាប់ក៏ពិតមែន ប៉ុន្តែយើងក៏នូវតែមានលក្ខខណ្ឌមួយចំនួនដែលត្រូវបានគេចាត់ទុកវាថាជា មូលហេតុដែលរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌ ដើម្បីបង្កើតឲ្យមាននូវការការពារសិទ្ធិ ។

ដូចមានរៀបរាប់ជូននៅក្នុងសារណានេះទាំងមូល ដែលនៅក្នុងសារណានេះផងដែរសុទ្ធសឹងតែបានធ្វើការបកស្រាយអំពីមូលហេតុដែលការរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌនេះ គឺយើងឃើញហើយថាច្បាប់ប្រទេសយើងបានបញ្ញត្តិយ៉ាងច្បាស់នៅក្នុងក្រមព្រហ្មទណ្ឌថ្មី និងចាស់។ មូលហេតុដែលរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌ ដែលមានបញ្ញត្តិនៅក្នុងក្រមព្រហ្មទណ្ឌមានដូចជា **យុត្តិកម្មនៃបទល្មើស** ដែលនេះគឺជាការបញ្ជាដោយច្បាប់ ឬ ដោយអាជ្ញាធរ លើការការពារស្របច្បាប់ និងស្ថានភាពចាំបាច់ ដែលនៅក្នុងករណីនីមួយៗសុទ្ធតែត្រូវតម្រូវឲ្យគោរពលក្ខខណ្ឌដែលច្បាប់បានកំណត់ទើបអំពើទាំងអស់នោះអាចកំណត់បានថា ជាមូលហេតុដែលរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌពិតប្រាកដ ហើយមិនតែប៉ុណ្ណោះ គឺនៅមានភាពមិនអាចទម្លាក់កំហុសបានមួយផ្នែកទៀតដែលក្រមព្រហ្មទណ្ឌថ្មីបានធ្វើការកម្រិតពីការដាក់ទណ្ឌកម្ម គឺការមិនដាក់ទោសពន្ធនាគារដល់ជនទាំងឡាយណាដែលត្រូវបានរកឃើញថា ជននោះមានវិបល្លាសស្មារតីនៅក្នុងពេលប្រព្រឹត្តបទល្មើស និងអនីតិជនជាដើម ។ ក្រៅពីមូលហេតុទាំងពីខាងលើ វាជាមូលហេតុមួយ

ដែលពាក់ព័ន្ធទៅនឹងការអនុវត្តជាក់ស្តែងនៅក្នុងសង្គមនាពេលបច្ចុប្បន្ននេះ ដែលត្រូវបានចាត់ទុកថាជាការរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌផងដែរ ពីព្រោះជាមូលហេតុដែលត្រូវបានក្រុមអ្នកច្បាប់ និងស្ថាប័នតុលាការ ទទួលស្គាល់ថាជាអំពើស្របច្បាប់ដែលកើតឡើងតាមច្បាប់ធម្មជាតិ ស្របច្បាប់សីលធម៌ដែលបានកើតមកពីក្នុងពូជនៃមនុស្ស ។ ដូចនេះខ្លឹមសារនៅក្នុងសារណានេះទាំង មូលគឺបានបង្ហាញឲ្យឃើញថាទង្វើខ្លះ ដែលមានការបំពានទៅលើបុគ្គលផ្សេងទៀតដែលធ្វើឲ្យប៉ះពាល់ដល់រូបកាយក្តី ទ្រព្យសម្បត្តិក្តី គឺទាំងអស់នោះវាមិនមែនជាបទល្មើសនោះទេ ព្រោះថាអំពើនោះបានស្តែងឡើងតាមរយៈការការពារ ការទប់ស្កាត់ ការរុញច្រាន ដែលវាជាការទទួលស្គាល់ដោយច្បាប់ដែលកំពុងតែអនុវត្តន៍ ។

# អនុសាសន៍

ដើម្បីឲ្យមូលហេតុនៃការរួចផុតពីការទទួលខុសត្រូវនេះ ឲ្យមន្ត្រីរាជការ ក៏ដូចជាប្រជាពលរដ្ឋបានយល់ដឹងបានកាន់តែច្បាស់នោះ ខ្ញុំបាទទាំងពីរនាក់សូមអនុញ្ញាតផ្តល់ជូននូវ អនុសាសន៍មួយចំនួនដូចខាងក្រោម៖

• សូមសំណូមពរដល់ថ្នាក់ដឹកនាំក្រសួងយុត្តិធម៌ មេត្តាចាត់វិធានការបន្ថែមដល់មន្ត្រីរាជការគ្រប់ជាន់ថ្នាក់បន្តផ្សព្វផ្សាយ ក្រមព្រហ្មទណ្ឌនេះ ដល់ប្រជាពលរដ្ឋឲ្យបានដឹងកាន់តែច្បាស់ពីក្រមមួយនេះ ។

• សូមសំណូមពរដល់ស្ថាប័នតុលាការមេត្តាស៊ើបសួរ និងរកភស្តុតាងឲ្យបានច្បាស់លាស់សិនមុននឹងធ្វើការជំនុំជម្រះ ដើម្បីជាភាពយុត្តិធម៌ដល់មហាជន ។

• សូមសំណូមពរដល់អាជ្ញាធរសាធារណៈមេត្តាពិនិត្យអំពីស្ថានភាពនៃបទល្មើស និងស្រាវជ្រាវឲ្យបានច្បាស់សិនមុននឹងធ្វើកំណត់ហេតុដាក់ជូនទៅព្រះរាជអាជ្ញា នេះដើម្បីពង្រឹងនឹងបង្ហាញឲ្យឃើញពីការអនុវត្តន៍យ៉ាងមុតមាំទៅតាមដំណើរឆ្ពោះទៅកាន់នីតិរដ្ឋរបស់ប្រទេសកម្ពុជា ។

• សូមសំណូមពរដល់រដ្ឋបាលថ្នាក់ក្រោមជាតិមេត្តាជួយចាត់វិធានការ ឬ ជួយសម្រួលដល់អាជ្ញាធរដែលមានសមត្ថកិច្ចក្នុងការផ្សព្វផ្សាយក្រមព្រហ្មទណ្ឌនេះ ។

• សូមសំណូមពរដល់គ្រឹះស្ថានឧត្តមសិក្សា និងគ្រប់សាកលវិទ្យាល័យទាំងអស់គួរតែបញ្ចូលកម្មវិធីសិក្សាអំពីមុខវិជ្ជាច្បាប់ជាពិសេសពី ក្រមព្រហ្មទណ្ឌនេះ ដល់សិស្ស និស្សិតដែលមកសិក្សានៅសាលារបស់ខ្លួន ។

• សូមសំណូមពរដល់អ្នកដែលមានជំនាញខាងផ្នែកច្បាប់ ដូចជាលោកបណ្ឌិត លោក-លោកស្រីសាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ ខាងផ្នែកច្បាប់ដែលសរសេរសៀវភៅច្បាប់ដែលមានការបកស្រាយក្បោះក្បាយ ងាយយល់ ងាយចាប់បាន ដើម្បីឲ្យអ្នកដែលមិនចេះច្បាប់ចេត្រឹមតែអានអក្សរអាចយល់បានកាន់តតែច្បាស់អំពីច្បាប់ ។

• សូមសំណូមពរដល់គ្រប់ស្ថានីយ៍ទូរទស្សន៍ ស្ថានីយ៍វិទ្យុ ប្រព័ន្ធអ៊ីនធឺណែត បើកឲ្យមាននូវកម្មវិធីផ្តល់យោបល់ និងបកស្រាយផ្នែកជំនាញច្បាប់ ក្នុងគោលបំណងផ្សព្វផ្សាយអំពីវិស័យច្បាប់នៅកម្ពុជា ដើម្បីជាប្រយោជន៍ដល់អ្នកសិក្សាផ្នែកច្បាប់ ក៏ដូចជាអ្នកដែលមានបញ្ហាក្នុងវិស័យច្បាប់នេះផងដែរ ។

• សូមសំណូមពរដល់បណ្តាប្រជាពលរដ្ឋទាំងអស់ មេត្តាព្យាយាមសិក្សាស្វែងយល់អំពីច្បាប់ដែលរាជរដ្ឋាភិបាលបានដាក់ចេញ និងត្រូវតែទទួលយក និងជួយគ្នាអនុវត្តទាំងអស់គ្នា ដើម្បីជាការធានាឲ្យច្បាប់មួយមាននិរន្តភាព និងជួយឲ្យប្រទេសកម្ពុជាក្លាយទៅជានីតិរដ្ឋយ៉ាងពិតប្រាកដ។

# ឯកសារយោង

## ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

១. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
២. ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩
៣. ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧
៤. ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៦
៥. ក្រមព្រហ្មទណ្ឌឆ្នាំ១៩៦៧ ចេញផ្សាយដោយលោក អេង សុត
៦. ច្បាប់ព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌ សំរាប់អនុវត្តនៅប្រទេសកម្ពុជាក្នុងសម័យអន្តរកាល និង ច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ
៧. ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ចុះថ្ងៃទី០២ ខែមករា ឆ្នាំ២០១២

## វចនានុក្រម និងសន្ទានុក្រម

១. វចនានុក្រមខ្មែរសម្តេចសង្ឃរាជ ជួនណាត ចេញផ្សាយដោយវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត ឆ្នាំ ១៩៦៧
២. វចនានុក្រមខ្មែរ-អង់គ្លេស អងគ្លេស-ខ្មែរ បោះពុម្ពលើទី១ ឆ្នាំ២០១២ រក្សាសិទ្ធដោយ ហ៊ីង ធីឫទ្ធិ (របស់លោក ភូ ឡាយស៊ិន និងលោក ភូ វួចចេង)
៣. សន្ទានុក្រមពាក្យច្បាប់ខ្មែរ អង់គ្លេស បារាំង ផ្នែកព្រហ្មទណ្ឌ ចេញផ្សាយដោយទីស្តីការគណៈរដ្ឋមន្ត្រី ឆ្នាំ២០១១

## ប្រភេទសៀវភៅ

១. សិក្ខាសាលាស្តីពីផលប៉ះពាល់នៃឥទ្ធិពលគ្រឿងញៀន ក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ នីតិគ្រួសារ និង ដំណោះស្រាយជំលោះអន្តរជាតិ, ថ្ងៃទី១៨ ១៩ ២០ ខែតុលា ឆ្នាំ២០១០
២. នីតិព្រហ្មទណ្ឌទូទៅ, ជួន ប៊ុនធី
៣. នីតិព្រហ្មទណ្ឌទូទៅ, រុន ពណ្ណារិទ្ធ ឆ្នាំ២០១២ កែសម្រួលដោយ ចាំង ស៊ីណាត
៤. នីតិព្រហ្មទណ្ឌទូទៅ, ហ៊ី សោភា
៥. នីតិព្រហ្មទណ្ឌទូទៅ, ហ៊ាង ឡេង
៦. នីតិព្រហ្មទណ្ឌទូទៅ, កៅ សីហា
៧. នីតិព្រហ្មទណ្ឌទូទៅ, យស់ ម៉ាច
៨.នីតិព្រហ្មទណ្ឌទូទៅ, ខាំ សុមករា
៩. នីតិព្រហ្មទណ្ឌទូទៅ, សេង ពុទ្ធី
១០. សេចក្តីផ្តើមនីតិនៃកម្ពុជា ឆ្នាំ២០១០
១១. សារណាបញ្ចប់ការសិក្សារបស់ លោក ហុង សម្បត្តិ និងលោកស្រី និល ហ្វីលីប (ឆ្នាំ២០០២) ។